ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# សីលធម៌ពលរដ្ឋវិជ្ជា

សម្រាប់

## កម្រិតមធ្យមសិក្សាទុតិយភូមិ

២០១៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៥០៤ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា កម្រិតមធ្យមសិក្សាទុតិយភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ ..**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិ**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ .-**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិនេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្តីផ្តើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាទុតិយភូមិជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អត.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សានិងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតមធ្យមសិក្សាទុតិយភូមិនេះ បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ព្រមទាំងផ្តល់នូវចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃ អង្គារ ៧រោច ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ការអប់រំបណ្តុះបណ្តាលសិស្សានុសិស្សឱ្យមានលក្ខណសម្បត្តិប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែកគឺធ្វើឱ្យពួកគេមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីក្លាយជាពលរដ្ឋពេញលេញសម្រាប់កសាងអនាគតនិងការចូលរួមអភិវឌ្ឍប្រទេសជាតិ។

ការវិវឌ្ឍនៃការកែលម្អកម្មវិធីសិក្សា គឺឆ្ពោះទៅរកគុណភាពអប់រំនិងធ្វើឱ្យមានជីវភាពរស់នៅកាន់តែល្អប្រសើរដោយបង្កើនការសិក្សាឱ្យផ្សារភ្ជាប់កម្មវិធីសិក្សាទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជា ទាំងមុខវិជ្ជាវិទ្យាសាស្ត្រ ទាំងមុខវិជ្ជាសិក្សាសង្គម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងវិនិយោគិនផងដែរ។

កម្មវិធីសិក្សាលម្អិតមុខវិជ្ជាសីលធម៌ពលរដ្ឋវិជ្ជា ត្រូវបានរៀបចំឡើងដោយផ្អែកលើកម្មវិធីសិក្សាលម្អិតសិក្សាសង្គមសម្រាប់អប់រំមូលដ្ឋានឆ្នាំ២០០៦ កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅឆ្នាំ២០០៦ ស្តង់ដាកម្មវិធីសិក្សា សិក្សាសង្គមឆ្នាំ២០០៦ ការអប់រំប្រឆាំងនឹងអំពើពុករលួយ ការអប់រំស្តីពីពលរដ្ឋសកល ការអប់រំស្តីពីសុវត្ថិភាពចរាចរណ៍ បញ្ចូលការគ្រប់គ្រងហិរញ្ញវត្ថុ ច្បាប់ជាតិ ក្របខណ្ឌកម្មវិធីសិក្សា អប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស និងស្ថានភាពអប់រំនៃបណ្តាប្រទេសក្នុងសហគមន៍អាស៊ាន ដូចជាសិង្ហបុរី ម៉ាឡេស៊ី ថៃ។ល។ ដែលធានាឱ្យអ្នកសិក្សាមានសមត្ថភាពចូលរួមក្នុងសកម្មភាពសង្គមនិងបន្តការសិក្សានៅគ្រប់គ្រឹះស្ថានសិក្សានានាទាំងក្នុងប្រទេសទាំងក្រៅប្រទេស។

កម្មវិធីសិក្សានេះបានកែលម្អខ្លឹមសារសំខាន់ៗ លទ្ធផលរំពឹងទុក របាយម៉ោង ការណែនាំអនុវត្ត ការវាយតម្លៃ វិធីសាស្ត្របង្រៀន និងតារាងកម្មវិធីសិក្សាលម្អិតចាប់ពីថ្នាក់ទី១០ដល់ថ្នាក់ទី១២ ហើយដែលលទ្ធផលរំពឹងទុកនឹងបង្ហាញដល់គ្រូបង្រៀន មាតាបិតា និងមន្ត្រីអប់រំគ្រប់កម្រិតឱ្យដឹងថា នៅពេលដែលសិស្សបានសិក្សាចប់កម្រិតថ្នាក់នីមួយៗនឹងទទួលបាននូវសមត្ថភាពពេញលេញ។

អនុគណៈកម្មការមុខវិជ្ជាឯកទេសសីលធម៌ពលរដ្ឋវិជ្ជានៅកម្រិតមធ្យមសិក្សាទុតិយភូមិ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានជំរុញ បង្កលក្ខណៈឱ្យមានការរៀបចំកម្មវិធីសិក្សាលម្អិតនេះប្រកបដោយជោគជ័យ ហើយអនុគណៈកម្មការនេះរីករាយនឹងទទួលយករាល់មតិកែលម្អពីសំណាក់លោកគ្រូអ្នកគ្រូ និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសសីលធម៌ពលរដ្ឋវិជ្ជា**

# មាតិកា


| | | |
|---|---|---|
| **ប្រកាស** | | i |
| **បុព្វកថា** | | iii |
| **អារម្ភកថា** | | iv |
| **មាតិកា** | | v |
| **១-** | **សេចក្តីផ្តើម** | 1 |
| **២-** | **គោលបំណង** | 1 |
| **៣-** | **គោលគំនិតៗសំខាន់ៗ** | 4 |
| **៤-** | **របាយម៉ោងសិក្សា** | 5 |
| **៥-** | **ការណែនាំអនុវត្ត** | 5 |
| **៦-** | **ការវាយតម្លៃ** | 7 |
| **៧-** | **តារាងកម្មវិធីសិក្សា** | 9 |
| | ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០ | 9 |
| | ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១ | 21 |
| | ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២ | 32 |
| **៨-** | **ឯកសារយោង** | 44 |
| **៩-** | **បញ្ជីឈ្មោះគណៈកម្មការ** | 45 |

## ១- សេចក្តីផ្តើម

មនុស្សជាភាវៈដែលមានវិចារណញ្ញាណ និងមានតម្រូវការគ្មានទីបញ្ចប់ ។ ហេតុដូចនេះហើយទើបមនុស្ស ស្វែងរកតម្រូវការរបស់ខ្លួនគ្រប់ពេលវេលា ដែលជាហេតុនាំឱ្យមនុស្សបង្កើតបាន វប្បធម៌ ជំនឿ សាសនា សង្គម និង វិទ្យាសាស្ត្រ ដើម្បីបម្រើសេចក្តីត្រូវការរបស់ខ្លួន។ វិទ្យាសាស្ត្របានរីកចម្រើនខ្លាំងតាំងពីសតវត្សទី១៩ រហូតដល់សតវត្សទី២១ ហើយសព្វថ្ងៃក៏បានក្លាយជាអាវុធមុខពីរ។ ដោយសារបញ្ហាវិទ្យាសាស្ត្រ និងការប្រកួតប្រជែងគ្រឿងសព្វាវុធ ក៏ដូចជាសេដ្ឋកិច្ច ពាណិជ្ជកម្ម ជាហេតុនាំឱ្យមនុស្សជួបប្រទះភាពស្មុគស្មាញ និងធ្វើឱ្យមានបញ្ហាប្រឈម ក្នុងការរស់នៅព្រមទាំងប្រឈមមុខដាក់គ្នាគ្រប់ពេលវេលា ។

ដោយសារបញ្ហាទាំងនេះហើយ ទើបមនុស្សបាននឹងកំពុងខិតខំរិះរកវិធីដោះស្រាយ និងស្វែងរកគោលការណ៍សីលធម៌ល្អៗមកអប់រំមនុស្ស បញ្ជ្រាបការយល់ដឹង ពីបញ្ហាប្រឈមទាំងនោះដល់មនុស្សគ្រប់គ្នាឱ្យបានយល់ដឹងច្បាស់លាស់ ជាពិសេសអប់រំដល់ពលរដ្ឋពិភពលោកទាំងមូលឱ្យយល់ដឹង និងងាកមករកសន្តិភាពទាំងផ្លូវគំនិត ស្មារតី សម្ភារៈ និងឱ្យតម្លៃមនុស្សដូចគ្នា ។ ជាទូទៅ មនុស្សចាំបាច់ត្រូវមានសីលធម៌ក្នុងការរស់នៅ ចេះគោរពគ្នា ចេះស្រឡាញ់គ្នាក្នុងនាមជាមនុស្សដែលរស់នៅលើផែនដីតែមួយជាមួយគ្នា ជាពិសេសធ្វើយ៉ាងណាធ្វើឱ្យពិភពលោកមានសន្តិភាព មានការអភិវឌ្ឍប្រកបដោយចីរភាព និងមានសុខដុមនីយកម្មដោយសន្តិភាព។ នៅក្នុងបរិបទនេះ ការអប់រំសីលធម៌ពលរដ្ឋវិជ្ជា បានដើរតួនាទីយ៉ាងសំខាន់ដើម្បីឆ្លើយតបនឹងតម្រូវការ និងដោះស្រាយបញ្ហាខាងលើតាមរយៈការអប់រំរបស់មុខវិជ្ជានេះ ។

នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជា "សីលធម៌-ពលរដ្ឋវិជ្ជា" បានផ្តោតជាសំខាន់លើការអប់រំសិស្សានុសិស្ស ឱ្យក្លាយជាពលរដ្ឋដែលមាន តម្លៃសកល មានលក្ខណៈសម្បត្តិជាមនុស្សពេញលេញ ជាពលរដ្ឋល្អដែលចេះគោរពច្បាប់ជាតិ និងច្បាប់អន្តរជាតិ ឬគោរពបទដ្ឋានគតិយុត្តផ្សេងៗ ព្រមទាំងឱ្យចេះគោរពពិពិធភាពរបស់មនុស្ស ដែលមានលក្ខណៈមិនដូចគ្នាតាំងពីធម្មជាតិ បណ្តុះឱ្យមានសេចក្តីស្រឡាញ់ ចូលរួមថែរក្សាតម្លៃខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមជាតិប្រកបដោយសុខសន្តិភាព បណ្តុះឱ្យពលរដ្ឋយកចិត្តទុកដាក់ចំពោះពិភពលោក ក៏ដូចជាមនុស្សជាតិទាំងអស់ដែលរស់នៅលើផែនដីតែមួយជាមួយគ្នា ។

នៅក្នុងខ្លឹមសារនៃកម្មវិធីសិក្សា "សីលធម៌-ពលរដ្ឋវិជ្ជា" បានដឹកនាំអ្នកសិក្សាឱ្យចេះធ្វើការស្រាវជ្រាវចំពោះបញ្ហាផ្សេងៗ ឱ្យចេះរៀនបន្ត និងរៀនពេញមួយជីវិត ព្រមទាំងចេះគោរពវប្បធម៌របស់មនុស្សជាតិ ដើម្បីក្លាយជាពលរដ្ឋពេញលេញ ស្អាតស្អំរបស់សង្គម និងពិភពលោកទាំងមូល ។

## ២- គោលបំណង

គោលបំណងនៃការអប់រំ "សីលធម៌ពលរដ្ឋវិជ្ជា" នៅថ្នាក់ទី១០ ទី១១ និងទី១២ គឺអប់រំសិស្សឱ្យស្គាល់ពីតម្លៃគុណធម៌ តម្លៃមនុស្ស (តម្លៃគំនិត ស្មារតី មនសិការ តម្លៃសម្បទា និងតម្លៃសីលធម៌) តម្លៃសង្គម-វប្បធម៌ និងមានការទទួលខុសត្រូវខ្ពស់លើសកម្មភាព និងការសម្រេចចិត្តរបស់ខ្លួន។ ធ្វើឱ្យបុគ្គលមានការជឿជាក់លើខ្លួនឯង មានឥរិយាបថវិជ្ជមានជាមួយអ្នកដទៃ មានសីលធម៌ សុជីវធម៌ក្នុងការរស់នៅ ព្រមទាំងចេះដោះស្រាយបញ្ហាផ្សេងៗក្នុងគ្រួសារ និងសហគមន៍ក៏ដូចជាសង្គមជាតិទាំងមូល។ អប់រំសិស្សឱ្យចេះថែទាំសុខភាព ទាំងផ្លូវចិត្ត ផ្លូវកាយ និងផ្លូវបញ្ញា ហើយចេះដោះស្រាយបញ្ហានានាដែលប្រឈមដោយសន្តិវិធី។ ជាពិសេសឱ្យអ្នកសិក្សាចូលរួមថែរក្សាវប្បធម៌ អរិយធម៌ អត្តសញ្ញាណជាតិ ព្រមទាំងផ្តល់ចំណេះដឹងផ្នែកសិទ្ធិមនុស្ស និងផ្នែកច្បាប់សំខាន់ៗរបស់ប្រទេសក៏ដូចជាច្បាប់អន្តរជាតិ។ មុខវិជ្ជានេះព្យាយាមធ្វើយ៉ាងណាឱ្យអ្នកសិក្សាមានការយល់ដឹង អំពីជីវភាពរស់នៅរបស់សង្គម បណ្តុះ

ការយល់ដឹង និងក្តីស្រឡាញ់ចំពោះទឹកដី បណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៃចរិយាធម៌ និងចរិកលក្ខណៈរបស់ប្រជាពលរដ្ឋខ្មែរម្នាក់ៗ ឱ្យពលរដ្ឋស្គាល់ពីភាពចាំបាច់ក្នុងនាមជាសមាជិកសង្គម ជាអ្នកកសាង និងអភិវឌ្ឍសង្គមឱ្យមានភាពសម្បូរសប្បាយរុងរឿងក្នុងបែបបទប្រជាធិបតេយ្យ។ ជាងនេះទៅទៀត អប់រំមនុស្សឱ្យចេះគោរពប្រតិបត្តិច្បាប់របស់ប្រទេស ដើម្បីចូលរួមជួយថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់ និងអភិវឌ្ឍសង្គម ដោយវៀរចាកអំពើអវិជ្ជមាន ដែលសង្គមស្អប់ខ្ពើម ព្រមទាំងចូលរួមកសាងវប្បធម៌សន្តិភាពសម្រាប់ទាំងអស់គ្នា។ បណ្តុះមនសិការអ្នកសិក្សាឱ្យគោរព និងប្រតិបត្តិច្បាប់ប្រពៃណី ទំនៀមទម្លាប់របស់ប្រទេស ឱ្យចូលរួមជួយថែរក្សា អភិរក្ស ព្រមទាំងយកចិត្តទុកដាក់ចូលរួមកសាងវប្បធម៌សន្តិភាព អភិវឌ្ឍសង្គមប្រកបដោយនិរន្តរភាព និងយល់ដឹងអំពីទំនាក់ទំនងល្អក្នុងតំបន់ និងពិភពលោក ។

កម្មវិធីសិក្សា "សីលធម៌ពលរដ្ឋវិជ្ជា" ផ្តល់ឱ្យអ្នកសិក្សានូវចំណេះដឹងមួយចំនួនទៀត ដូចមានក្នុងកថាខណ្ឌខាងក្រោម៖

- បណ្តុះសិស្សឱ្យយល់ដឹងអំពីសកម្មភាពផ្សេងៗរបស់សង្គម ក្នុងន័យចូលរួមថែរក្សា ការពារសុវត្ថិភាព ជីវភាពរស់នៅប្រកបដោយផាសុកភាពសម្រាប់ខ្លួនឯង ពលរដ្ឋ និងមានបរិស្ថានរស់នៅស្អាត ខ្យល់អាកាសល្អបរិសុទ្ធ
- បណ្តុះឱ្យសិស្សដឹងខ្លួនឯងថា ជាសមាជិកម្នាក់របស់សង្គមដែលត្រូវចូលរួមទទួលខុសត្រូវ រាល់បញ្ហាសង្គមដែលកើតមានឡើង និងចូលរួមថែរក្សាការពារសង្គមរបស់ខ្លួនឱ្យបានល្អប្រសើរឡើង
- បណ្តុះសិស្សឱ្យមានមោទនភាព មានក្តីស្រឡាញ់ចំពោះខ្លួនឯង គ្រួសារ សហគមន៍ សង្គមជាតិ ឈានទៅស្រឡាញ់តំបន់ និងពិភពលោកទាំងមូល
- បណ្តុះឱ្យសិស្សមានសមត្ថភាពក្នុងការគិតពិចារណា អំពីលក្ខណៈពិសេសនៃបាតុភូតសង្គម បាតុភូតធម្មជាតិ ដោះស្រាយបញ្ហាជាមួយគ្នា ព្រមទាំងបណ្តុះសមត្ថភាព សហការគ្នា ជួយគ្នា ព្រមទាំងចេះបញ្ចេញ ឬបង្ហាញចេញនូវអ្វីដែលខ្លួនបានគិត និងបានស្រាវជ្រាវ ព្រមទាំងធ្វើការចែករំលែកដល់គ្នាដោយស្មារតីសន្តិភាព
- បណ្តុះឱ្យសិស្សមានការយល់ដឹងអំពី ការប្រើប្រាស់លទ្ធិប្រជាធិបតេយ្យ ការបោះឆ្នោត និងនយោបាយដែលអាស្រ័យរដ្ឋធម្មនុញ្ញរបស់ជាតិ ព្រមទាំងឱ្យយល់ដឹងអំពីទំនាក់ទំនងនៃភាពខុសគ្នារវាងអំណាចទាំងបីគឺ អំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការរបស់កម្ពុជា ។

ដើម្បីសម្រេចគោលបំណងរួមនៃការអប់រំ "សីលធម៌ពលរដ្ឋវិជ្ជា" ថ្នាក់ទី១០ ទី១១ និងទី១២ សិស្សនឹងទទួលបានសមាសភាគបីសំខាន់ៗជាមូលដ្ឋានគ្រឹះដូចខាងក្រោម៖

### ២.១- វិជ្ជាសម្បទា

- ផ្តល់ឱ្យអ្នកសិក្សានូវចំណេះដឹងអំពីតម្លៃ និងគុណធម៌សំខាន់ៗ របស់ទស្សនវិទូក្នុងពិភពលោក ព្រមទាំងឱ្យចេះវិធីរៀបចំខ្លួន និងធ្វើខ្លួនជាមនុស្សមានតម្លៃក្នុងសង្គម
- បណ្តុះអ្នកសិក្សាឱ្យស្គាល់អំពីប្រវត្តិកំណើតនៃសាសនា ជំនឿផ្សេងៗ មានការយល់ដឹងពីទំនាក់ទំនងរវាងសាសនា និងច្បាប់សង្គមជាដើម
- ឱ្យសិស្សមានចំណេះដឹងអំពីច្បាប់ សិទ្ធិមនុស្សសំខាន់ៗ លទ្ធិប្រជាធិបតេយ្យ សិទ្ធិពលរដ្ឋ និងទំនួលខុសត្រូវ ឬសិទ្ធិបោះឆ្នោត
- ឱ្យសិស្សយល់ដឹងពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន និងសារៈសំខាន់នៃការថែទាំសុខភាពទាំងផ្លូវចិត្ត ផ្លូវកាយ បញ្ញាស្មារតី និងចេះថែទាំសុខភាពផ្លូវចិត្តរបស់ខ្លួនឱ្យបានល្អ
- ឱ្យសិស្សស្គាល់អំពីបញ្ញារបស់មនុស្ស ទំនោរនៃធម្មជាតិមនុស្ស និងការរស់នៅប្រកបដោយតម្លៃ ព្រមទាំងមានចំណេះដឹងអំពីគុណធម៌ សុជីវធម៌ សមធម៌ សីលធម៌ ប្រពៃណីទំនៀមទម្លាប់ និងសាសនាដែលប្រជាពលរដ្ឋគោរពប្រតិបត្តិ

- ឱ្យសិស្សយល់ដឹងអំពីទំនាក់ទំនងរវាងសិទ្ធិ និងច្បាប់ រដ្ឋបាលសាធារណៈ ប្រព័ន្ធរដ្ឋាភិបាល ស្ថាប័នតុលាការនៅប្រទេសកម្ពុជា ការគ្រប់គ្រងរដ្ឋតាមបែបប្រព័ន្ធវិមជ្ឈការ ឬសហវិមជ្ឈការ ។
- ឱ្យសិស្សមានចំណេះដឹងអំពីច្បាប់ សិទ្ធិមនុស្ស ទំនាក់ទំនងសិទ្ធិមនុស្ស ជាមួយទស្សន វិស័យមួយចំនួនរបស់សាសនា សង្គម និងច្បាប់រដ្ឋ
- ឱ្យសិស្សយល់ដឹងពីទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងបណ្ដាប្រទេសនានានៅក្នុងតំបន់ និងនៅលើពិភពលោក ។

## ២.២- បំណិនសម្បទា

- ឱ្យសិស្សស្គាល់ថាអ្វីទៅជាតម្លៃមនុស្ស គ្រួសារ សង្គម ដែលមនុស្សត្រូវការ និងចង់បាន ព្រមទាំង ធ្វើយ៉ាងណាឱ្យចេះដោះស្រាយបញ្ហាដោយគុណធម៌ និងការទទួលខុសត្រូវ
- ឱ្យសិស្សអនុវត្ត និងគោរពតាមច្បាប់ (ធម្មជាតិ សង្គម និងសាសនា) របស់ប្រទេស ដោយចូលរួម និងជួយថែរក្សាសណ្ដាប់ធ្នាប់ សុវត្ថិភាព និងអភិវឌ្ឍសង្គមជាតិរបស់ខ្លួន
- ឱ្យសិស្សមានភាពប៉ិនប្រសព្វក្នុងការដោះស្រាយបញ្ហា ពិចារណាអំពីក្រម ច្បាប់ ដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណីជាដើម
- ឱ្យសិស្សអនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួន ក្នុងនាមជាប្រជាពលរដ្ឋ ជាម្ចាស់ប្រទេស ស្របតាមអ្វីដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា
- ឱ្យសិស្សមានសមត្ថភាព វិភាគ វាយតម្លៃ អំពីសារៈសំខាន់នៃសាសនា តួនាទី និងភារកិច្ចសាសនា នៅក្នុងសង្គមកម្ពុជាក៏ដូចជាក្នុងពិភពលោក
- ឱ្យសិស្សចេះបង្ហាញ និងប្រើប្រាស់វិធីកម្សាន្តងាយៗក្នុងជីវិតរស់នៅ និងចៀសឱ្យផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើអបាយមុខខុសច្បាប់ ដែលអាចបំផ្លាញខ្លួនឯង គ្រួសារ និងសង្គម និងឱ្យមានបំណិនថែទាំសុខភាពផ្លូវចិត្ត និងបញ្ញាស្មារតីរបស់ខ្លួន
- ឱ្យសិស្សបង្ហាញឱ្យឃើញពីតម្លៃជាមនុស្ស តម្លៃសង្គម វប្បធម៌ សាសនា ប្រកបដោយការទទួលខុសត្រូវ និងអាចប្រើប្រាស់បំណិនរបស់ខ្លួនសម្រាប់ធ្វើការសម្រេចចិត្តបានត្រឹមត្រូវ
- ឱ្យសិស្សអនុវត្ត និងគោរពច្បាប់ប្រទេស សាសនាឱ្យបានល្អ មានសុភវិនិច្ឆ័យ ចូលរួមជួយថែរក្សាសុវត្ថិភាព សណ្ដាប់ធ្នាប់គ្រួសារ និងសង្គម ដើម្បីឱ្យសង្គមមានស្ថិរភាព និងវឌ្ឍនភាព
- ឱ្យសិស្សពណ៌នា និងពន្យល់បានពីអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ រួមទាំងការគ្រប់គ្រងរដ្ឋបាលថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ មូលដ្ឋាន និងការអនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនក្នុងនាមជាប្រជាពលរដ្ឋ ។
- ឱ្យសិស្សមានសមត្ថភាពវិភាគពីសារៈសំខាន់នៃការធ្វើទំនាក់ទំនងល្អ ការរស់នៅល្អ ជាមួយអ្នកដទៃ ស្ថាប័ន សង្គម និងពិភពលោក ។

## ២.៣- ចរិយាសម្បទា

- ឱ្យសិស្សគោរព និងឱ្យតម្លៃលើខ្លួនឯង អ្នកដទៃ សង្គម និងពិភពលោក
- ឱ្យសិស្សប្រកាន់ខ្ជាប់នូវសីលតម្លៃ និងគុណធម៌ បណ្ដុះស្មារតីចូលរួមជួយថែរក្សា អភិវឌ្ឍ សហគមន៍ សង្គម ដោយមនសិការសីលធម៌ខ្ពស់ និងមានការទទួលខុសត្រូវខ្ពស់ក្នុងការរស់នៅ
- ឱ្យសិស្សមានចិត្តស្រឡាញ់ជីវិតខ្លួនឯង ក្រុមគ្រួសារ សង្គម ដោយមិនប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង និងល្បែងស៊ីសង
- បណ្ដុះស្មារតីសិស្សឱ្យចូលរួម ជួយអភិវឌ្ឍសហគមន៍ សង្គមជាតិ និងអន្តរជាតិ

- ឱ្យសិស្សមានការទទួលខុសត្រូវខ្ពស់ ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដោយមិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃ តាមរយៈការប្រតិបត្តិ និងគោរពច្បាប់ ជាពិសេស ច្បាប់ សិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ
- ឱ្យសិស្សគោរព និងឱ្យតម្លៃលើសេរីភាព ជំនឿសាសនា ការប្រតិបត្តិសាសនា និងរក្សាអត្តសញ្ញាណជាតិរបស់ខ្លួន និងមានទំនាក់ទំនងល្អជាមួយសង្គមអន្តរជាតិ ។

## ៣- គោលគំនិតសំខាន់ៗ

ប្រធានបទសំខាន់ៗនៃកម្មវិធីសិក្សា “សីលធម៌ពលរដ្ឋវិជ្ជា” មានបួនជំពូកសំខាន់ៗគឺ ជំពូកទី១ តម្លៃមនុស្ស ជំពូកទី២ ទំនាក់ទំនងល្អក្នុងសហគមន៍ ជំពូកទី៣ វប្បធម៌ និងសាសនា និងជំពូកទី៤ សង្គមយើង។ នៅក្នុងចំណោមមេរៀនទាំងបួនជំពូកនេះ មិនមានលក្ខណៈដូចគ្នាទេ ក្នុងចំណោមថ្នាក់ទី១០ ទី១១ និងទី១២ តែមេរៀនភាគច្រើនមានទំនាក់ទំនងគ្នា។ ខ្លឹមសារមេរៀននៃកម្រិតថ្នាក់នីមួយៗនឹងផ្តល់សមត្ថភាពដល់អ្នកសិក្សាមានលក្ខណៈជាប្រព័ន្ធ និងស្របតាមទ្រឹស្តីប្លូមតាក់សូណូមី (Bloom’s Taxonomy) ដូចជា ដំណាក់កាលដំបូងផ្តល់ចំណេះដឹង (ការចងចាំ) រួចឈានដល់ការយល់ដឹង ការអនុវត្ត ការវិភាគ ឬការសំយោគ(ការវាយតម្លៃ) និងការវាយតម្លៃ (ការបង្កើតថ្មី)។ ខ្លឹមសារមេរៀនទាំងបីកម្រិតនេះ ឆ្លងកាត់ពីកម្រិតទាប ទៅកម្រិតខ្ពស់ និងស្របតាម ការវិវឌ្ឍខួរក្បាលរបស់សិស្ស ដោយស្របតាមការរីកចម្រើនរបស់សង្គម និងពិភពលោក ។

**ខ្លឹមសារជំពូកទី១៖ តម្លៃមនុស្ស**

ក្នុងជំពូកនេះផ្តោតជាសំខាន់លើ៖
- បណ្តុះមនសិការអ្នកសិក្សា ឱ្យស្រឡាញ់ការសិក្សា ចេះកសាង និងការពារជាតិមាតុភូមិ
- បណ្តុះការគោរព និងប្រើប្រាស់ច្បាប់ សិទ្ធិ និងសេរីភាពរបស់ខ្លួនបានត្រឹមត្រូវ
- បណ្តុះឱ្យមានសីលធម៌ល្អ ចេះទទួលខុសត្រូវនូវទង្វើរបស់ខ្លួន ហ៊ានធ្វើហ៊ានទទួល មានស្មារតីល្អ ភ្ញាក់រលឹកខ្ពស់ក្នុងនាមជាពលរដ្ឋរបស់សង្គម និងពិភពលោក
- បណ្តុះការត្រិះរិះពិចារណា ឱ្យចេះវិភាគ វិនិច្ឆ័យ និងវាយតម្លៃបញ្ហាបានត្រឹមត្រូវ
- បណ្តុះការចូលរួម ថែរក្សា ការពារសុខភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូររបស់ខ្លួន គ្រួសារ សង្គម និងមនុស្សជាតិ ក្នុងនាមជាពលរដ្ឋថ្លៃថ្នូរ
- បណ្តុះឱ្យមានគំនិតច្នៃប្រឌិត ចេះបង្កើតថ្មី និងអភិរក្សនូវអ្វីដែលមានទុកជាមរតកជាតិ និងមនុស្សជាតិ ។

**ខ្លឹមសារជំពូកទី២៖ ទំនាក់ទំនងល្អក្នុងសហគមន៍**

ក្នុងជំពូកនេះផ្តោតជាសំខាន់លើ៖
- បណ្តុះឱ្យស្គាល់ និងថែរក្សាអត្តសញ្ញាណ ជាតិកំណើត (បុគ្គល ក្រុម សង្គម និងពិភពលោក)
- បណ្តុះឱ្យគោរពពិពិធភាព និងមានទំនាក់ទំនងល្អរវាង បុគ្គល ក្រុមគ្រួសារ សហគមន៍ ជាតិ និងពិភពលោក និងចូលរួមដោះស្រាយជម្លោះគ្រប់ប្រភេទឱ្យស្ថិតក្នុងសន្តិភាព
- បណ្តុះឱ្យស្គាល់ពីតួនាទី ភារកិច្ច កាតព្វកិច្ច ក្នុងការធ្វើទំនាក់ទំនងជាមួយពលរដ្ឋ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់
- បណ្តុះសេចក្តីស្រឡាញ់ និងចូលរួមថែរក្សាទ្រព្យសម្បត្តិសាធារណៈ
- បណ្តុះឱ្យយល់ដឹងពីលទ្ធិប្រជាធិបតេយ្យ ។

**ខ្លឹមសារជំពូកទី៣៖ វប្បធម៌ សាសនា និងការអប់រំ**

ក្នុងជំពូកនេះផ្តោតជាសំខាន់លើ៖

- បណ្តុះសិស្សឱ្យយល់ដឹង និងចូលរួមថែរក្សាវប្បធម៌ អរិយធម៌ ទំនៀមទម្លាប់ប្រពៃណី និងមានមោទនភាពជាតិខ្មែរ
- បណ្តុះការគោរព ស្រឡាញ់ ដឹងគុណ និងតបស្នងសងគុណមាតាបិតា
- បណ្តុះឱ្យស្គាល់ពីប្រវត្តិ និងទស្សនៈសំខាន់ៗនៃសាសនាធំៗក្នុងពិភពលោក
- បណ្តុះឱ្យចេះគោរពពិពិធភាព ចំពោះអ្នកកាន់សាសនាផ្សេងៗ (វប្បធម៌ និងសាសនា) និងកសាងដោយសុខដុមនីយកម្មក្នុងសាសនា និងសង្គម
- បណ្តុះឱ្យប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌សកល ។

**ខ្លឹមសារក្នុងជំពូកទី៤៖ សង្គមយើង**

ក្នុងជំពូកនេះផ្តោតជាសំខាន់លើ៖

- បណ្តុះសិស្សឱ្យមានទំនួលខុសត្រូវក្នុងនាមជាសមាជិកសង្គម ចូលរួមកសាង និងអភិវឌ្ឍសង្គមដោយវឌ្ឍនភាព
- បណ្តុះការគោរពច្បាប់ជាតិ សាសនា សិទ្ធិមនុស្ស និងច្បាប់អន្តរជាតិផ្សេងៗ
- បណ្តុះការស្រឡាញ់មនុស្សជាតិ និងបរិស្ថាន
- បណ្តុះឱ្យមានសីលធម៌រស់នៅល្អ
- បណ្តុះឱ្យចេះរៀបចំ និងធ្វើផែនការសម្រាប់អនាគត ខ្លួនឯង និងសង្គម
- បណ្តុះឱ្យចូលរួមលុបបំបាត់អំពើពុករលួយ និងមានគណនេយ្យភាពសង្គម
- បណ្តុះឱ្យក្លាយជាពលរដ្ឋអាស៊ាន ចេះគោរពច្បាប់អាស៊ាន សិទ្ធិស្ត្រី សិទ្ធិមនុស្ស និងចូលរួមរកយុត្តិធម៌ឱ្យមនុស្សក្នុងសង្គម ។

## ៤- របាយម៉ោងសិក្សា

| កម្រិតថ្នាក់ | សប្តាហ៍ | ចំនួនម៉ោង/សប្តាហ៍ | | រយៈពេលសិក្សា | ចំនួនម៉ោងក្នុងមួយឆ្នាំសិក្សា | |
|---|---|---|---|---|---|---|
| | | វិទ្យាសាស្ត្រ | វិទ្យាសាស្ត្រសង្គម | | វិទ្យាសាស្ត្រ | វិទ្យាសាស្ត្រសង្គម |
| ១០ | ៣៥ | ២ម៉ោង | ៣ម៉ោង | ៥០នាទី | ៧០ម៉ោង | ១០៥ម៉ោង |
| ១១ | ៣៥ | ២ម៉ោង | ៣ម៉ោង | ៥០នាទី | ៧០ម៉ោង | ១០៥ម៉ោង |
| ១២ | ៣៥ | ២ម៉ោង | ៣ម៉ោង | ៥០នាទី | ៧០ម៉ោង | ១០៥ម៉ោង |

## ៥- ការណែនាំអនុវត្ត

ដើម្បីអនុវត្តកម្មវិធីសិក្សា “សីលធម៌-ពលរដ្ឋវិជ្ជា” ឱ្យបានជោគជ័យគ្រូត្រូវ៖

- ធ្វើសកម្មភាពរៀន និងបង្រៀនដោយប្រមូលផ្តុំសិស្សនៅក្នុងថ្នាក់រៀន បែងចែកសិស្សជាក្រុម ហើយគ្រូបង្រៀនជាអ្នកសម្របសម្រួល និងធ្វើជាអ្នកណែនាំដល់សិស្សានុសិស្ស
- ត្រូវបញ្ជ្រាបការអប់រំពីតម្លៃ ការអប់រំពលរដ្ឋសកល ព្រមទាំងការអប់រំពលរដ្ឋវិជ្ជានៅគ្រប់សកម្មភាពបង្រៀន និងរៀនទាំងក្នុងមុខវិជ្ជាឯកទេស និងមុខវិជ្ជារងរបស់កម្មវិធីសិក្សា

- ត្រូវផ្អែកលើការអង្កេតជាមូលដ្ឋាន ដោយតម្រូវឱ្យសិស្សចេះធ្វើការសង្កេត តាមវិធីផ្សេងៗ ដើម្បីស្វែងរក និងផ្តល់ព័ត៌មានត្រឡប់អំពីប្រធានបទដែលបានដាក់ឱ្យ ដូចជាកិច្ចផ្ទះ ឬកិច្ចការស្រាវជ្រាវជាដើម
- ត្រូវជំរុញ លើកទឹកចិត្ត និងបណ្តុះស្មារតីសិស្ស ឱ្យចូលរួមធ្វើសកម្មភាពសិក្សាផ្សេងៗ ដូចជា ចូលរួមលេងល្បែងកម្សាន្ត ល្បែងដើរតួ ឡើងធ្វើបទបង្ហាញ ជ្រើសរើស ធ្វើតំណាងក្រុម និងស្វែងរកអំណះអំណាងដើម្បីការពារគំនិតរបស់ខ្លួន ឬក្រុមខ្លួន
- ត្រូវបង្រៀនសិស្សពីភាពងាយស្រួល រួចឈានទៅដល់ភាពស្មុគស្មាញ ពីរូបីទៅអរូបី និងធ្វើឱ្យមានភាពងាយស្រួល ងាយយល់ និងចៀសវាងប្រើប្រាស់ពាក្យពេចន៍ដែលមិនសមស្រប ក្នុងវ័យសិក្សារបស់សិស្ស
- ត្រូវប្រើសម្ភារឧបទេសឱ្យបានត្រឹមត្រូវតាមខ្លឹមសារមេរៀន និងការអនុវត្តការងារគម្រូឱ្យបានច្រើនជាអតិបរិមាសម្រាប់សិស្ស
- ត្រូវបង្ហាញរូបគម្រូ និងណែនាំសិស្សឱ្យសង្កេត ពិនិត្យតាមដាន និងដាក់សម្ភារៈសម្រាប់ឱ្យសិស្សធ្វើនៅចំពោះមុខ
- ត្រូវប្រាប់ដំណឹងឱ្យសិស្សចេះស្វែងរកសម្ភារៈត្រៀមទុកជាមុនយ៉ាងតិចមួយថ្ងៃ មុនពេលបង្រៀនមេរៀនជាក់ស្តែង ដែលពាក់ព័ន្ធ
- ត្រូវជំរុញ និងលើកទឹកចិត្តដល់សិស្ស ឱ្យហ៊ានសួរសំណួរ និងឆ្លើយសំណួរគ្រូ និងត្រូវបណ្តុះសិស្សឱ្យចេះស្រាវជ្រាវ វិភាគ ពិចារណា សំយោគ និងអនុវត្ត ដើម្បីប្រើប្រាស់ក្នុងសហគមន៍ និងសង្គមរបស់ខ្លួន ។

**ការប្រតិបត្តិរបស់សិស្ស**

ក្រោយពីបញ្ចប់ការសិក្សាលើមុខវិជ្ជា “សីលធម៌-ពលរដ្ឋវិជ្ជា” សិស្សអាចប្រតិបត្តិបាននូវគោលការណ៍មួយចំនួនដូចខាងក្រោម៖

- ចេះគោរព ឱ្យតម្លៃមនុស្ស សត្វ បរិស្ថាន សាសនា សង្គម និងវប្បធម៌ផ្សេងគ្នា
- ចេះរស់នៅជាមួយគ្នា ជាក្រុម សហគមន៍ សង្គម និងចុះសម្រុងជាមួយមនុស្សដទៃដែលមាននិន្នាការខុសគ្នា
- ធ្វើខ្លួនជាពលរដ្ឋល្អរបស់គ្រួសារ សហគមន៍ សង្គម និងពិភពលោក
- ចេះប្រើប្រាស់សមត្ថភាព ជំនាញ ទេពកោសល្យ និងបំណិនពីការរៀនរបស់ខ្លួនជា ប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងសង្គម
- ធ្វើខ្លួនជាពលរដ្ឋ ដែលចេះគោរពច្បាប់សង្គម ច្បាប់ធម្មជាតិ ប្រពៃណី ទំនៀមទម្លាប់ និងសាសនារបស់ខ្លួន និងពិភពលោក
- ធ្វើខ្លួនឱ្យក្លាយជាពលរដ្ឋល្អរបស់សង្គម និងពិភពលោកដែលមានអារ្យធម៌ខ្ពង់ខ្ពស់
- ចេះជួយគ្នា មានទំនាក់ទំនងល្អជាមួយគ្នា អ្នកជិតខាង មានសីលធម៌ក្នុងការរស់នៅល្អ មានសាមគ្គីភាព ស្រឡាញ់ជាតិ សាសនា ព្រះមហាក្សត្រ ។

**វិធីសាស្ត្របង្រៀន**

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ វិធីសាស្ត្របង្រៀន ជាចំណុចអាទិភាពមួយក្នុងការបញ្ជ្រាបចំណេះដឹងប្រកបដោយប្រសិទ្ធភាពពីសំណាក់គ្រូបង្រៀន។ វិធីសាស្ត្របង្រៀនត្រូវផ្សារភ្ជាប់ទៅនឹងទ្រឹស្តីនិងការអនុវត្តផ្ទាល់ ជាពិសេសពាក់ព័ន្ធក្នុងជីវភាពរស់នៅជាក់ស្តែងរបស់សិស្ស ។

**គោលការណ៍ទី១៖** មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ត្រូវបង្រៀនតាមគោលវិធីសាស្ត្រសិស្សមជ្ឈមណ្ឌលដែលក្នុងនោះតម្រូវឱ្យសិស្សមានសកម្មភាពរស់រវើកនិងច្រើនជាងគ្រូបង្រៀន ដើម្បីឱ្យសម្រេចបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ក្នុងមេរៀននីមួយៗស្របតាមដំណើរវិវឌ្ឍរបស់សង្គម និងពិភពលោក ។

**គោលការណ៍ទី២៖** ការបង្រៀនត្រូវតែជួយណែនាំ គាំទ្រ និងលើកទឹកចិត្តសិស្ស ឱ្យចេះរៀន ឬសិក្សាស្រាវជ្រាវដោយខ្លួនឯង។ គ្រូត្រូវចេះវិធីសាស្ត្របង្រៀន យល់ដឹងពីការលូតលាស់បញ្ញា សម្បទារបស់សិស្ស ដើម្បីឱ្យសិស្សមានការចេះត្រិះរិះពិចារណា ស្គាល់ខ្លួនឯងច្បាស់ ស្គាល់អ្នកដទៃ ចេះគោរពខ្លួនឯង និងអ្នកដទៃ ព្រមទាំងហ៊ានជជែកវែកញែក ដេញដោលរកហេតុផល ហ៊ានបញ្ចេញគំនិត និងទទួលស្គាល់នូវគំនិតរបស់អ្នកដទៃ ។ វិធីសាស្ត្រទាំងនេះរួមមានដូចជា វិធីពិភាក្សា វិធីអនុមានរួម អនុមានញែក វិធីជជែកវែកញែក ឬវិធីសាស្ត្រករកជាដើម និងវិធីសាស្ត្រផ្សេងៗទៀតតាមតែអាចធ្វើបាន ។

**គោលការណ៍ទី៣៖** ការបង្រៀនត្រូវផ្តល់ឱ្យសិស្សនូវវិជ្ជាសម្បទា បំណិនសម្បទា ឱ្យគេបន្តពង្រឹង និងពង្រីកចំណេះដឹង បទពិសោធទេពកោសល្យ ក៏ដូចជាចំណង់ចំណូលចិត្ត ដើម្បីឱ្យ ស្រឡាញ់ និងឱ្យតម្លៃលើការសិក្សារបស់ខ្លួន ។

**គោលការណ៍ទី៤៖** ការប្រើប្រាស់វិធីសាស្ត្របង្រៀន ត្រូវផ្អែកលើខ្លឹមសារមេរៀន ផ្អែកលើសមត្ថភាពរបស់សិស្សក្នុងការទទួលចំណេះដឹង និងត្រូវផ្សារភ្ជាប់ទៅនឹងបរិស្ថាននៅជុំវិញ រួមជាមួយនឹងសម្ភារឧបទេស បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដ៏សម្បូរបែប ។

**គោលការណ៍ទី៥៖** បង្កើតឱ្យមានការអនុវត្តជាក់ស្តែង ដោយផ្អែកលើខ្លឹមសារមេរៀន និងធ្វើយ៉ាងណាឱ្យសិស្សបានចូលរួមនៅក្នុងកម្មវិធីសង្គមនានាដូចជា ពិធីអាពាហ៍ពិពាហ៍ សិក្ខាសាលា ការតាំងពិព័ណ សិល្បៈ របាំ ល្បែងប្រពៃណីជាតិ តាមរយៈការសង្កេតដោយផ្ទាល់ ជាពិសេសអំពីវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ជាតិ ពិធីបុណ្យសាសនារបស់ជនជាតិផ្សេងៗ និងឱ្យពួកគេអាចចូលរួមដោយផ្ទាល់ក្នុងការងារអភិវឌ្ឍសហគមន៍ ។

ទោះបីជាយ៉ាងនេះក៏ដោយយើងសង្កេតឃើញថា ការប្រើវិធីសាស្ត្របង្រៀន មានភាពចាំបាច់ទោះបីជាពុំទាន់មានវិធីសាស្ត្រណាមួយដែលល្អឥតខ្ចោះ ឬមានលក្ខណៈល្អគ្រប់ជ្រុងជ្រោយ សម្រាប់ប្រើប្រាស់ក្នុងការរៀន និងបង្រៀនក៏ដោយ។ មានន័យថា ពីមេរៀនមួយ ទៅមេរៀនមួយ លោកគ្រូ-អ្នកគ្រូត្រូវប្រើវិធីសាស្ត្រផ្សេងៗដែលស្របតាមខ្លឹមសារមេរៀន។ គ្រូបង្រៀនត្រូវមាន បច្ចេកទេសបង្រៀន និងចេះប្រើប្រាស់សម្ភារឧបទេសផ្សេងៗ ប្រកបដោយប្រសិទ្ធភាព ហើយអាចសម្រេចបាននូវគោលបំណង និងខ្លឹមសារមេរៀនទាំងស្រុងបាន ។

## ៦- ការវាយតម្លៃ

ការវាយតម្លៃជាចំណុចសំខាន់ដែលគ្រប់ភូមិសិក្សាត្រូវយកចិត្តទុកដាក់
សម្រាប់ធ្វើការតាមដានការសិក្សារបស់សិស្ស ដែលជាត្រីវិស័យសម្រាប់នាំទៅរកគុណភាព និងប្រសិទ្ធភាពនៃការរៀន និងការបង្រៀន ។ ការវាយតម្លៃសំដៅលើការប្រមូលព័ត៌មាន ឬភស្តុតាងនានាដើម្បីធ្វើសេចក្តីសន្និដ្ឋាន ធ្វើការសម្រេចចិត្តនិងរកវិធីកែលម្អដំណើរការរៀននិងបង្រៀន។ ការវាយតម្លៃត្រូវផ្តោតលើសូចនាករបីសំខាន់គឺ វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលសិស្សទទួលបានពីការសិក្សា។ ការវាយតម្លៃមានមុខងារ តម្រង់ទិសនៃការរៀន និងការបង្រៀន ដើម្បីឱ្យសម្រេចបាននូវវត្ថុបំណងរបស់មេរៀន និងដើម្បីវាស់វែងលទ្ធផល និងសមត្ថភាពសិក្សារបស់សិស្ស ដើម្បីឆ្លើយតបទៅនឹងលទ្ធផលសិក្សាស្តង់ដាកម្មវិធីសិក្សាដែលបានរំពឹងទុកក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ។

ការវាយតម្លៃ ជាការវាស់ស្ទង់សមត្ថភាពសិស្ស ដើម្បីឱ្យដឹងអំពីលទ្ធផលសិក្សា ថាតើទទួលបានលទ្ធផលសិក្សាកម្រិតណា ដោយផ្អែកលើកម្មវិធីសិក្សាលម្អិតស្តង់ដានេះ ។ ការវាយតម្លៃមានច្រើនប្រភេទ ដូចនេះគ្រូបង្រៀនអាចធ្វើការវាយតម្លៃមេរៀននីមួយៗ តាមរយៈការវាយតម្លៃបឋម ដែលនឹងត្រូវធ្វើឡើងនៅមុនពេលចាប់ផ្តើមមេរៀន ដើម្បីដឹងអំពីកម្រិតចំណេះដឹងរបស់សិស្សម្នាក់ៗ ។ ការវាយតម្លៃនៅពាក់កណ្តាលវគ្គ ឬវាយតម្លៃតាមដំណាក់កាល ដើម្បីដឹង និងទទួលបានព័ត៌មានត្រឡប់អំពីការយល់ដឹងខ្លឹមសារមេរៀន និងវិធីសាស្ត្របង្រៀនរបស់លោកគ្រូ អ្នកគ្រូ។ ការវាយតម្លៃសរុប ជាទូទៅតែងធ្វើឡើងនៅចុងបញ្ចប់នៃមេរៀន និងវគ្គសិក្សានីមួយៗ ដើម្បីវាស់វែងលទ្ធផលសម្រេច ក្រោយពីសិស្សបានរៀនចប់មេរៀននីមួយៗ ប៉ុន្តែការវាយតម្លៃនេះជាទូទៅត្រូវបានធ្វើឡើងជាប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំ។

ការវាយតម្លៃមានគោលបំណងមួយចំនួនដូចតទៅ ៖

- ដើម្បីវាស់កម្រិតចំណេះដឹង បំណិន និងសម្បទារបស់សិស្ស ក្រោយពីបានសិក្សាចប់មេរៀន ជំពូក ឬកម្មវិធីសិក្សានានាតាមថ្នាក់ និងតាមកម្រិតសិក្សានីមួយៗ
- ដើម្បីវាស់កម្រិតនៃការប្រែប្រួល ឬការរីកចម្រើនផ្លូវចិត្ត បញ្ញា និងគុណតម្លៃនានារបស់សិស្ស ដូចជាតម្លៃសីលធម៌ ឥរិយាបថ សាមគ្គីភាព ការស្រឡាញ់វប្បធម៌ ឬប្រពៃណីជាតិ ។ល។
- ដើម្បីឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការរៀន និងការបង្រៀន ដែលផ្តល់ព័ត៌មានត្រឡប់ឱ្យគ្រូ សិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា និងអ្នកអប់រំ ដើម្បីរកមធ្យោបាយលើកកម្ពស់គុណភាពនៃការរៀន និងការបង្រៀនឱ្យកាន់តែល្អប្រសើរឡើង ។ ជាពិសេស ការផ្តល់ព័ត៌មានត្រឡប់ទាំងនោះនឹងធ្វើឱ្យសិស្សដឹងអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ដើម្បីជួយតម្រង់ទិសការរៀន និងការបង្រៀន ឱ្យកាន់តែមានគុណភាព មានប្រសិទ្ធភាពខ្ពស់ និងសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា
- ដើម្បីផ្តល់ទិន្នន័យជាប្រទីប សម្រាប់ជួយដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់សិស្សម្នាក់ៗ ចំពោះអនាគត និងការសិក្សាបន្តរបស់គេថែមទៀត ។

**លក្ខខណ្ឌក្នុងការវាយតម្លៃ**

ដើម្បីឱ្យលទ្ធផលនៃការវាយតម្លៃមានប្រសិទ្ធភាព និងប្រកបដោយជោគជ័យ លោកគ្រូ អ្នកគ្រូត្រូវកំណត់ឱ្យបានច្បាស់លាស់អំពី៖

- វត្ថុបំណងវង្វាយតម្លៃ (ដើម្បីអ្វី)
- សមត្ថភាព ឬបំណិនដែលត្រូវវាយតម្លៃ (លើអ្វី)
- កម្រិតវាយតម្លៃ (ត្រឹមណា)
- រូបភាព ឬឧបករណ៍វាយតម្លៃ (សំណេរ ផ្ទាល់មាត់ សម្តែងតួ ប្រត្តិបត្តិ ការសង្កេតផ្ទាល់)
- កាលបរិច្ឆេទវាយតម្លៃ(ពេលណា)
- រយៈពេលវាយតម្លៃ (ប៉ុន្មាននាទី ឬប៉ុន្មានម៉ោង) ។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០

- ថ្នាក់វិទ្យាសាស្ត្រសង្គម១០៥ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១សប្តាហ៍/៣ម៉)
- ថ្នាក់វិទ្យាសាស្ត្រ ៧០ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១សប្តាហ៍/២ម៉)

ក្នុងចំណោមមេរៀនថ្នាក់ទី១០ទាំងបួនជំពូកត្រូវបង្រៀនថ្នាក់វិទ្យាសាស្ត្រក្នុងមួយមេរៀនចំនួន២ម៉ោង

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : តម្លៃមនុស្ស** | | |
| **មេរៀនទី១: សញ្ញាណទស្សនវិជ្ជា**<br>១.១- បញ្ញត្តិទស្សនវិជ្ជា<br>១.២- មែកធាងទស្សនវិជ្ជា<br>១.៣- វិធីទស្សនវិជ្ជា<br>១.៤- លទ្ធិទស្សនវិជ្ជា<br>១.៥- សារៈសំខាន់នៃការសិក្សាទស្សនវិជ្ជា | **វិជ្ជាសម្បទា**<br>- ពណ៌នាបានអំពីបញ្ញត្តិ ទស្សនវិជ្ជា វិធីទស្សនវិជ្ជា មែកធាង លទ្ធិទស្សនវិជ្ជា និងទស្សនវិទូ សារៈសំខាន់នៃទស្សនវិជ្ជា។<br>**បំណិនសម្បទា**<br>- បង្ហាញបានអំពីបញ្ញត្តិ ទស្សនវិជ្ជា មែកធាង លទ្ធិទស្សនវិជ្ជា និងទស្សនវិទូ។<br>**ចរិយាសម្បទា**<br>- មានស្មារតីស្រឡាញ់មុខវិជ្ជាទស្សនវិជ្ជា ប្រើប្រាស់វិធីទស្សនវិជ្ជាដោះស្រាយបញ្ហាក្នុងការរស់នៅប្រចាំថ្ងៃ។ | ៤ម៉ |
| **មេរៀនទី២ : សុភាវធម៌ និងព្រហ្មវិហារធម៌**<br>២.១- និយមន័យ<br>២.២- ធាតុផ្សំនៃសុភាវធម៌(សុជីវធម៌ សីលធម៌ គុណធម៌<br>២.៣- ធាតុផ្សំនៃព្រហ្មវិហារធម៌(មេតា ករុណា មុទិតា ឧបេខា)<br>២.៤- សារៈសំខាន់នៃសុភាវធម៌ និងព្រហ្មវិហារធម៌ | **វិជ្ជាសម្បទា**<br>- ពណ៌នាបានអំពីបញ្ញត្តិ សុភាវធម៌ (សីលធម៌ គុណធម៌ សុជីវធម៌) ព្រហ្មវិហារធម៌ និងសារៈសំខាន់នៃការប្រតិបត្តិ។<br>**បំណិនសម្បទា**<br>- បង្ហាញបានអំពីការប្រតិបត្តិ និងការទទួលខុសត្រូវប្រកបដោយសុភាវធម៌ (សីលធម៌ គុណធម៌ សុជីវធម៌) និងព្រហ្មវិហារធម៌។<br>**ចរិយាសម្បទា**<br>- បណ្តុះអាកប្បកិរិយាឱ្យមានសុភាវធម៌ (សុជីវធម៌ សីលធម៌ គុណធម៌) និងព្រហ្មវិហារធម៌។ | ៣ម៉ |
| **មេរៀនទី៣ : ការច្នៃប្រឌិត និងកម្មសិទ្ធបញ្ញា**<br>៣.១- និយមន័យ<br>៣.២- គោលការណ៍ក្នុងការអភិវឌ្ឍគំនិតច្នៃប្រឌិត និងកម្មសិទ្ធិបញ្ញា<br>៣.៣- ការប្រើប្រាស់បញ្ញាក្នុងការច្នៃប្រឌិត | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីនិយមន័យនៃការច្នៃប្រឌិត និងកម្មសិទ្ធិបញ្ញា<br>- ពណ៌នាបានពីតម្លៃនៃការប្រើប្រាស់ និងដោះស្រាយបញ្ហាដោយបញ្ញា។ | ៤ម៉ |

| | | |
|---|---|---|
| ៣.៤- វិធីដោះស្រាយបញ្ហាដោយបញ្ញា | **បំណិនសម្បទា**<br>- បង្ហាញបានពីរបៀបនៃការដោះស្រាយ និងការប្រើបញ្ញា។<br>**ចរិយាសម្បទា**<br>- បណ្តុះតម្លៃបញ្ញា ជាកម្លាំងក្នុងការច្នៃប្រឌិតដោះស្រាយបញ្ហានានានិងគោរពកម្មសិទ្ធិបញ្ញា។ | |
| **មេរៀនទី៤ : ការសម្រេចចិត្ត**<br>៤.១- ការកំណត់អាទិភាព<br>៤.២- លំនាំផែនការនៃការសម្រេចចិត្ត<br>៤.៣. ការទទួលខុសត្រូវ និងការសម្រេចចិត្ត<br>៤.៤- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ<br>៤.៥- លទ្ធផលនៃការសម្រេចចិត្ត | **វិជ្ជាសម្បទា**<br>- ពណ៌នាពីលំនាំនៃផែនការ ការសម្រេចចិត្តផ្សេងៗ និងផ្នែកហិរញ្ញវត្ថុ<br>**បំណិនសម្បទា**<br>- បង្ហាញពីគម្រោងក្នុងការសម្រេចចិត្តធ្វើអ្វីមួយ និងការសន្សំថវិកា<br>**ចរិយាសម្បទា**<br>- ទទួលខុសត្រូវចំពោះការសម្រេចចិត្ត និងការសន្សំថវិកា។ | ៣ម៉ |
| **មេរៀនទី៥ : ការផ្លាស់ប្តូរ និងការអភិវឌ្ឍខ្លួនឯង**<br>៥.១- និយមន័យ<br>៥.២- សារប្រយោជន៍នៃការអភិវឌ្ឍខ្លួន<br>៥.៣- ការផ្លាស់ប្តូរដោយភាពវិជ្ជមាន និងអវិជ្ជមាន<br>៥.៤- ភាពខុសគ្នារវាងការផ្លាស់ប្តូររបស់មនុស្ស និងធម្មជាតិ | **វិជ្ជាសម្បទា**<br>- ប្រាប់បានពីអត្ថន័យនៃការផ្លាស់ប្តូ និងអភិវឌ្ឍខ្លួន (ផ្នត់គំនិត ឥរិយាបថ និងសារពាង្គកាយ)។<br>**បំណិនសម្បទា**<br>- បកស្រាយបានពីសារប្រយោជន៍នៃការអភិវឌ្ឍខ្លួន និងការផ្លាស់ប្តូរជាវិជ្ជមាន។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់នូវការអភិវឌ្ឍខ្លួនក្នុងភាពវិជ្ជមានរវាងមនុស្ស និងធម្មជាតិ។ | ៤ម៉ |
| **មេរៀនទី៦ : លើកកម្ពស់ និងការពារសុខុមាលភាពបុគ្គល និងសមូហភាព**<br>៦.១- និយមន័យ<br>៦.២- យុទ្ធសាស្ត្រក្នុងការលើកកម្ពស់សុខភាពសហគមន៍<br>៦.៣- សុខុមាលភាពពលរដ្ឋ និងទំនួលខុសត្រូវរបស់រដ្ឋ<br>៦.៤- ការចូលរួមរបស់ពលរដ្ឋក្នុងការលើកកម្ពស់សុខុមាលភាពសហគមន៍ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីអត្ថន័យ និងយុទ្ធសាស្ត្រក្នុងការលើកកម្ពស់សុខភាពសហគមន៍ (ការអប់រំកាយ សុវត្ថិភាពចំណី អាហារ បរិស្ថានរស់នៅស្អាត)។<br>**បំណិនសម្បទា**<br>- បង្ហាញសកម្មភាពចូលរួមការពារសុខុមាលភាពបុគ្គល និងពលរដ្ឋ (ភូមិ-ឃុំ មានសុវត្ថិភាព)។ | ៣ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ស្រឡាញ់ខ្លួន សហគមន៍ និងចូលរួម អភិវឌ្ឍសហគមន៍។ | |
| **មេរៀនទី៧ : ពលរដ្ឋល្អ ស្អាតស្អំ**<br>៧.១- និយមន័យ<br>៧.២- លក្ខណៈសម្បត្តិពលរដ្ឋល្អស្អាតស្អំ<br>៧.៣- គុណតម្លៃ និងឥរិយាបថពលរដ្ឋល្អស្អាតស្អំ<br>៧.៤- កាតព្វកិច្ចពលរដ្ឋស្អាតស្អំ និងការកសាង សន្តិភាព<br>៧.៥- សិទ្ធិ និងការទទួលខុសត្រូវរបស់ពលរដ្ឋ ចំពោះសង្គមជាតិ និងអន្តរជាតិ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ និងគុណតម្លៃពលរដ្ឋល្អស្អាតស្អំ<br>- ពណ៌នាលក្ខណៈពលរដ្ឋល្អស្អាតស្អំ ចំពោះខ្លួនឯង គ្រួសារ និងសមូហភាព<br>**បំណិនសម្បទា**<br>- បកស្រាយពីកាតព្វកិច្ចពលរដ្ឋល្អស្អាតស្អំ និងការកសាងសន្តិភាព<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ និងចូលរួមថែរក្សាសន្តិភាព | ៣ម៉ |
| **មេរៀនទី៨ : តម្រូវការ និងសិទ្ធិ**<br>៨.១- និយមន័យ<br>៨.២- តម្រូវការ និងសិទ្ធិមនុស្ស<br>៨.៣- តម្រូវការ និងសិទ្ធិពលរដ្ឋនៅមូលដ្ឋាន<br>៨.៤- វិធីផ្លាស់ប្តូរខ្លួនឯង និងសង្គម តាមរយៈតម្រូវការ និងសិទ្ធិ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីនិយមន័យ តម្រូវការ និងសិទ្ធិ<br>- រៀបរាប់ពីតម្រូវការ Abraham Maslow និងសិទ្ធិ<br>- ពណ៌នាទំនាក់ទំនងរវាងតម្រូវការ និងសិទ្ធិ ពលរដ្ឋនៅមូលដ្ឋាន។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់សិទ្ធិ និងតម្រូវការដើម្បីអភិវឌ្ឍ ខ្លួនឯង គ្រួសារ និងសហគមន៍។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់នូវគោលការណ៍ក្នុងការប្រើប្រាស់ តម្រូវការ និងសិទ្ធិឱ្យបានត្រឹមត្រូវ។ | ៣ម៉ |
| **មេរៀនទី៩ : សិទ្ធិ និងករណីយកិច្ចពលរដ្ឋ**<br>៩.១- និយមន័យ<br>៩.២- ប្រភេទសិទ្ធិមនុស្ស<br>៩.៣- គោលការណ៍នៃសិទ្ធិ និងករណីកិច្ច របស់ពលរដ្ឋ<br>៩.៤- សិទ្ធិជនជាតិភាគតិចនៅកម្ពុជា<br>៩.៥- ការការពារ និងលើកកម្ពស់របស់រាជរដ្ឋាភិបាល ចំពោះសិទ្ធិជនជាតិភាគតិចនៅកម្ពុជា | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីនិយមន័យករណីកិច្ចពលរដ្ឋ<br>- ពណ៌នាសិទ្ធិផ្សេងៗរបស់ពលរដ្ឋក្នុងសង្គម ប្រជាធិបតេយ្យៈ សិទ្ធិពលរដ្ឋ សិទ្ធិ នយោបាយ សិទ្ធិសេដ្ឋកិច្ច (សិទ្ធិទទួលបានព័ត៌មានហិរញ្ញវត្ថុ) សិទ្ធិ សង្គមកិច្ច សិទ្ធិវប្បធម៌ តាមរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ<br>- យល់ដឹងពីអត្តសញ្ញាណ សិទ្ធិ កាតព្វកិច្ច និងការចូលរួមនៃជនជាតិភាគតិចចំពោះ សង្គមនៅកម្ពុជា។ | ៣ម៉ |

| | | |
|---|---|---|
| | **បំណិនសម្បទា**<br>- ប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងនាមជាពលរដ្ឋ ដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរ<br>- ប្រើប្រាស់ និងគោរពសិទ្ធិជនជាតិភាគតិច ផ្សេងៗ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ភាពជាពលរដ្ឋល្អដែលចេះប្រើ ប្រាស់សិទ្ធិតាមគោលការណ៍ច្បាប់។ | |
| **មេរៀនទី១០ : គោលដៅនិងមធ្យោបាយនៃការចូលរួម**<br>១០.១- និយមន័យ<br>១០.២- ការចូលរួម និងបញ្ហាប្រឈមនៅមូលដ្ឋាន និងថ្នាក់ជាតិ<br>១០.៣- ការលើកកម្ពស់ការចូលរួម និងដំណោះស្រាយបញ្ហានៅមូលដ្ឋាន និងថ្នាក់ជាតិ<br>១០.៤- ផលប្រយោជន៍នៃការចូលរួមនៅមូលដ្ឋាន និងថ្នាក់ជាតិ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ គោលដៅ និងមធ្យោបាយ<br>- ពិភាក្សា សម្របសម្រួលដោះស្រាយបញ្ហាសង្គមនៅមូលដ្ឋាន និងថ្នាក់ជាតិ។<br>**បំណិនសម្បទា**<br>- កំណត់ជ្រើសរើសគោលដៅឱ្យស្របតាមច្បាប់សង្គម និងរកមធ្យោបាយជួយដោះស្រាយបញ្ហាផ្សេងៗ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់អាកប្បកិរិយាវិជ្ជមានក្នុងការប្រើប្រាស់មធ្យោបាយ និងគោលដៅដើម្បីចូលរួមអភិវឌ្ឍសហគមន៍។ | ៣ម៉ |
| **ជំពូកទី២ : ទំនាក់ទំនងល្អក្នុងសហគមន៍** | | |
| **មេរៀនទី១ : អត្តសញ្ញាណ**<br>១.១- និយមន័យ<br>១.២- ប្រភេទនៃអត្តសញ្ញាណ<br>១.៣- សារៈសំខាន់នៃអត្តសញ្ញាណ<br>១.៤- ការចូលរួមថែរក្សាអត្តសញ្ញាណជាតិ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យអត្តសញ្ញាណ<br>- ពណ៌នាពីប្រភេទ និងសារៈសំខាន់នៃអត្តសញ្ញាណបុគ្គល ជាតិ តំបន់ និងពិភពលោក។<br>**បំណិនសម្បទា**<br>- បង្ហាញ និងឱ្យតម្លៃអត្តសញ្ញាណខ្លួន និងអ្នកដទៃ។<br>**ចរិយាសម្បទា**<br>- ចូលរួមថែរក្សាអត្តសញ្ញាណជាតិ។ | ៣ម៉ |
| **មេរៀនទី២ : ការគោរពខ្លួនឯងនិងអ្នកដទៃ**<br>២.១- បញ្ញត្តិនៃសេចក្ដីស្រឡាញ់<br>២.២- ការអភ័យទោស<br>២.៣- មនុស្សស្មោះត្រង់<br>២.៤- សម្ដីវិជ្ជមាន | **វិជ្ជាសម្បទា**<br>- បង្ហាញបានពីតម្លៃនៃការគោរពខ្លួនឯង និងអ្នកដទៃ ភាពស្មោះត្រង់ ការដឹង និងទទួលកំហុស។ | |

| | | |
|---|---|---|
| ២.៥- ការប្រៀបធៀបខ្លួនឯង និងអ្នកដទៃ<br>២.៦- ភាពម្ចាស់ការលើខ្លួនឯង<br>២.៧- តម្លៃយើង<br>២.៨- ផលប្រយោជន៍នៃការគោរពខ្លួនឯង និងអ្នកដទៃ | **បំណិនសម្បទា**<br>- បង្ហាញមនសិការក្នុងការគោរពអ្នកដទៃ និងគោរពខ្លួនឯង និងភាពជាម្ចាស់ចិត្តលើខ្លួនឯង។<br>**ចរិយាសម្បទា**<br>- ប្រកាន់នូវឥរិយាបថវិជ្ជមានក្នុងការគោរព និងឱ្យតម្លៃខ្លួនឯង និងអ្នកដទៃ។ | |
| **មេរៀនទី៣ : សុភមង្គលគ្រួសារ**<br>៣.១- និយមន័យ<br>៣.២- អាពាហ៍ពិពាហ៍<br>៣.៣- កូន និងគ្រួសារ<br>៣.៤- មុខងារខាងផ្លូវសង្គម និងសីលវិជ្ជានៃគ្រួសារ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ សុភមង្គលគ្រួសារ<br>- ពណ៌នាពីលក្ខខណ្ឌនៃសុភមង្គលគ្រួសារ មានដូចជា៖ លក្ខខណ្ឌសម្ភារៈ លក្ខខណ្ឌវេទនា លក្ខខណ្ឌសីលវិជ្ជា និងលក្ខខណ្ឌសង្គម។<br>**បំណិនសម្បទា**<br>- បង្ហាញទំនាក់ទំនងរវាងកូន និងគ្រួសារ<br>- មុខងារខាងផ្លូវសង្គម និងសីលវិជ្ជានៃគ្រួសារ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់សមាជិកគ្រួសារ និងចូលរួមធ្វើឱ្យគ្រួសារមានសុភមង្គល។ | ៣ម៉ |
| **មេរៀនទី៤ : សហគមន៍សន្តិភាព**<br>៤.១- បញ្ញត្តិសន្តិភាព<br>៤.២- ការចេះអត់ឱន និងកែលម្អគ្នាជាភាតរភាព<br>៤.៣- ការចងសម្ព័ន្ធភាព<br>៤.៤- សមធម៌ និងយុត្តិធម៌<br>៤.៥- អភិបាលកិច្ចល្អ<br>៤.៦- ការប្រាស្រ័យទាក់ទង ចរចា និងការឥស៊ូមតិដោយសន្តិវិធី<br>៤.៧- ការលើកកម្ពស់អាកប្បកិរិយាសង្គមវិជ្ជមាន | **វិជ្ជាសម្បទា**<br>- ពណ៌នាពីការចេះអត់ឱន អធ្យាស្រ័យឱ្យអ្នកដទៃ និងសុខដុមនីយកម្មនៅក្នុងសហគមន៍ដោយសន្តិភាព។<br>**បំណិនសម្បទា**<br>- ផ្តល់ជាឧទាហរណ៍អំពីសារៈសំខាន់នៃការចេះអត់ឱន ការជួយកែលម្អគ្នា និងយុត្តិធម៌ក្នុងសហគមន៍។<br>**ចរិយាសម្បទា**<br>- មានស្មារតីជួយកែលម្អខ្លួនឯង បងប្អូន មិត្តភក្តិ ឬមិត្តរួមថ្នាក់<br>- ស្រឡាញ់សន្តិភាព យុត្តិធម៌ សមធម៌ សាមគ្គីធម៌។ | ៣ម៉ |
| **មេរៀនទី៥ : តួនាទី ភារកិច្ច និងការប្តេជ្ញាចិត្តរបស់ពលរដ្ឋ**<br>៥.១- តួនាទី និងកាតព្វកិច្ចពលរដ្ឋក្នុងកិច្ចការសង្គម<br>៥.២- ការប្តេជ្ញាចិត្តលើកកម្ពស់ និងការពារសុខុមាល | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីតួនាទី កាតព្វកិច្ច និងការចូលរួមកិច្ចការសង្គម<br>- ពណ៌នាវិធីនៃការលើកកម្ពស់ និងការពារ | ៣ម៉ |

| | | |
|---|---|---|
| ភាពបុគ្គល និងសមូហភាព<br>៥.៣- ការផ្តល់កម្លាំងចិត្តឱ្យមានការគាំទ្រពីពលរដ្ឋ<br>៥.៤- ការអប់រំឱ្យចូលរួមក្នុងសកម្មភាពអភិវឌ្ឍសង្គម | សុខុមាលភាពបុគ្គល និងសមូហភាព។<br>**បំណិនសម្បទា**<br>- បង្ហាញតួនាទីរបស់ពលរដ្ឋក្នុងការចូលរួមកសាង និងអភិវឌ្ឍសង្គម ។<br>**ចរិយាសម្បទា**<br>- ចូលរួមលើកកម្ពស់ និងការពារសុខុមាលភាពបុគ្គល និងសមូហភាព។ | |
| **មេរៀនទី៦** : **យេនឌ័រ និងហិរញ្ញវត្ថុ**<br>៦.១- និយមន័យ<br>៦.២- ភេទ យេនឌ័រ និងអំពើហិង្សា<br>៦.៣- យេនឌ័រ ការអប់រំ និងការអភិវឌ្ឍ<br>៦.៤- តួនាទីយេនឌ័រ និងហិរញ្ញវត្ថុ<br>៦.៥- សមភាព និងវិសមភាពយេនឌ័រ<br>៦.៦- សារៈសំខាន់នៃការគោរពតួនាទីយេឌ័រ | **វិជ្ជាសម្បទា**<br>- កំណត់បានពីនិយមន័យ យេនឌ័រ និងហិរញ្ញវត្ថុ<br>- ប្រាប់បានពីវិសមភាពអំណាច វិសមភាពសេដ្ឋកិច្ច ជម្លោះ ការរើសអើង និងការវិនិច្ឆ័យអវិជ្ជមានចំពោះយេឌ័រ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីតួនាទីយេនឌ័រ និងការប្រើប្រាស់ហិរញ្ញវត្ថុក្នុងសមភាពយេនឌ័រក្នុងគ្រួសារ ។<br>**ចរិយាសម្បទា**<br>- មានស្មារតីចូលរួមគោរព លើកកម្ពស់យេនឌ័រ និងតួនាទីស្ត្រី។ | ៣ម៉ |
| **មេរៀនទី៧** : **ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**<br>៧.១- ការគ្រប់គ្រងរដ្ឋបាល<br>៧.២- រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៧.៣- តួនាទី ភារកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៧.៤- តួនាទី ភារកិច្ចគណៈអភិបាល និងក្រុមប្រឹក្សា | **វិជ្ជាសម្បទា**<br>- ពណ៌នាពីការគ្រប់គ្រងរដ្ឋបាល និងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ<br>- បង្ហាញភាពខុសគ្នារវាងក្រុមប្រឹក្សា និងគណៈអភិបាល<br>- រៀបរាប់ពីតួនាទី ភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។<br>**បំណិនសម្បទា**<br>- បកស្រាយពីការគ្រប់គ្រងរដ្ឋបាល តួនាទី និងភារកិច្ចមូលដ្ឋាន។<br>**ចរិយាសម្បទា**<br>- ចូលរួមអនុវត្តអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៨ : យុវជន និងការអភិវឌ្ឍសហគមន៍**<br>៨.១- និយមន័យ<br>៨.២- តួនាទី ភារកិច្ចរបស់យុវជនកម្ពុជា<br>៨.៣- យុវជនជាកម្លាំងចលករនៃការអភិវឌ្ឍ<br>៨.៤- ការកសាងធនធានយុវជន<br>៨.៥- យុវជនគម្រូ | **វិជ្ជាសម្បទា**<br>- កំណត់ពីនិយមន័យ យុវជន និងការអភិវឌ្ឍ<br>- រៀបរាប់ពីតួនាទី ភារកិច្ចនិងចូលរួមដើម្បីអភិវឌ្ឍសហគមន៍ និងសង្គមជាតិ។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់តួនាទី ភារកិច្ច និងចូលរួមធ្វើការអភិវឌ្ឍសង្គមជាតិ។<br>**ចរិយាសម្បទា**<br>- មានស្មារតីភ្ញាក់រលឹក ចិត្តស្រឡាញ់ ចំពោះតួនាទីភារកិច្ចរបស់ខ្លួនក្នុងនាមជាយុវជន និងសមាជិកសង្គម។ | ៣ម៉ |
| **មេរៀនទី៩ : ឪពុកម្តាយ និងមរតក**<br>៩.១- និយមន័យ<br>៩.២- ទំនាក់ទំនងរវាងឪពុកម្តាយ និងកូនបង្កើត<br>៩.៣- ទំនាក់ទំនងរវាងឪពុកម្តាយ និងកូនស្មុំ<br>៩.៤- ការលែងលះ និងការបែងចែកទ្រព្យសម្បត្តិ<br>៩.៥- ការបែងចែក និងការទទួលមរតក | **វិជ្ជាសម្បទា**<br>- កំណត់ពីនិយមន័យ មរតក<br>- រៀបរាប់ពីទំនាក់ទំនងរវាងឪពុក ម្តាយ និងកូនតាមផ្លូវច្បាប់ ការបែងចែកទ្រព្យសម្បត្តិ និងមរតក។<br>**បំណិនសម្បទា**<br>- បង្ហាញលក្ខណៈសម្បត្តិសន្តតិជន ប្រភេទសន្តតិកម្ម និងទម្រង់មរតកសាសន៍ (បណ្តាំបុគ្គលស្លាប់)<br>- វែកញែកភាពខុសគ្នារវាងសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមបណ្តាំ និងករណីមិនអាចទទួលបានមរតក។<br>**ចរិយាសម្បទា**<br>- មានស្មារតីបំពេញតួនាទី និងកាតព្វកិច្ចក្នុងការទទួលមរតក ដែលច្បាប់បានកំណត់ពីសិទ្ធិទទួលមរតក។ | ៣ម៉ |
| **ជំពូកទី៣ : វប្បធម៌ និងសាសនា** | | |
| **មេរៀនទី១ : អរិយធម៌**<br>១.១- និយមន័យ<br>១.២- មែកធាងនៃអរិយធម៌<br>១.៣- ទំនាក់ទំនងរវាងវប្បធម៌ និងសង្គមធម៌<br>១.៤- ទំនាក់ទំនងរវាងអរិយធម៌ខ្មែរ និងអរិយធម៌បរទេស<br>១.៥- តម្លៃនៃអរិយធម៌ខ្មែរ<br>១.៦- បញ្ហាប្រឈមក្នុងការរស់នៅនៃពិពិធភាព | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យអរិយធម៌តាមទ្រឹស្តីទស្សនវិទូ<br>- ពណ៌នាពីទំនាក់ទំនងរវាងអរិយធម៌ធម៌ខ្មែរ និងអរិយធម៌បរទេស ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីមែកធាងអរិយធម៌ និងសារៈសំខាន់ អរិយធម៌ខ្មែរ។ | ៣ម៉ |

| | | |
|---|---|---|
| វប្បធម៌ | **ចរិយាសម្បទា**<br>- បណ្តុះស្មារតីឱ្យចូលរួមថែរក្សាអរិយធម៌ខ្មែរ។ | |
| **មេរៀនទី២ : ខ្មែរនីយកម្ម**<br>២.១- និយមន័យ<br>២.២- ដើមកំណើតជាតិខ្មែរ<br>២.៣- ការហូរចូលជនជាតិ និងវប្បធម៌ផ្សេងៗ<br>២.៤- ការធ្វើសង្គមនីយកម្មរបស់ខ្មែរ<br>២.៥- ភាពចាំបាច់នៃការធ្វើខ្មែរនីយកម្ម | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ខ្មែរនីយកម្ម<br>- ពណ៌នាបានសង្គមខ្មែរនីយកម្ម និងដើម កំណើតខ្មែរ។<br>**បំណិនសម្បទា**<br>- បកស្រាយបានពីខ្លឹមសារនៃសង្គមខ្មែរ នីយកម្ម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រឡាញ់ជាតិសាសន៍ វប្បធម៌ សង្គមនិងគាំទ្រផលិតផលជាស្នាដៃខ្មែរ។ | ៣ម៉ |
| **មេរៀនទី៣ : ជំនឿ និងទំនៀមទម្លាប់ខ្មែរ**<br>៣.១- ដើមកំណើតនៃជំនឿ និងការកកើត ទំនៀមទម្លាប់ខ្មែរ<br>៣.២- ការគោរពរបស់បុព្វបុរសខ្មែរ<br>៣.៣- ពិធីនានាក្នុងទំនៀមទម្លាប់ខ្មែរសេចក្តីសន្និដ្ឋាន | **វិជ្ជាសម្បទា**<br>- ស្គាល់ពីដើមកំណើតទំនៀមទម្លាប់ខ្មែរ និងពិធីនានាដែលខ្មែរមានតាំងពីបុរាណរហូត ដល់ពេលបច្ចុប្បន្ន<br>**បំណិនសម្បទា**<br>- អាចបកស្រាយ ពន្យល់បានពីជំនឿ និង ទំនៀមទម្លាប់ខ្មែរ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ ចូលរួមថែរក្សា និងអភិរក្សជំនឿ និងទំនៀមទម្លាប់ខ្មែរ។ | ៣ម៉ |
| **មេរៀនទី៤ : ពិធីបុណ្យប្រពៃណីជាតិ និងសាសនា**<br>៤.១- និយមន័យ<br>៤.២- ពិធីបុណ្យចូលឆ្នាំខ្មែរ<br>៤.៣- ពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ<br>៤.៤- ពិធីបុណ្យភ្ជុំបិណ្ឌ<br>៤.៥- ពិធិកត្តញ្ញូកត្តវេទី<br>៤.៥- ពិសាខបូជា<br>៤.៦- មាឃបូជា | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ បុណ្យប្រពៃណីជាតិ និងបុណ្យសាសនា<br>- បង្ហាញពីពិធីបុណ្យប្រពៃណីជាតិ និងបុណ្យ សាសនាក្នុងសង្គមខ្មែរដូចជា បុណ្យចូល ឆ្នាំខ្មែរ ពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ ភ្ជុំបិណ្ឌ ពិធីកត្តញ្ញូកត្ត វេទី ពិសាខបូជា និងមាឃបូជា។<br>**បំណិនសម្បទា**<br>- គោរពប្រតិបត្តិចំពោះពិធីបុណ្យចូលឆ្នាំខ្មែរ ពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ ភ្ជុំបិណ្ឌ ពិធិកត្តញ្ញូកត្តវេទី ពិសាខបូជា និងមាឃបូជា។ | ៣ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- បណ្តុះស្មារតីចូលរួមថែរក្សា ការពារ និងអភិរក្សពិធីបុណ្យប្រពៃណីជាតិ និងបុណ្យសាសនា។ | |
| **មេរៀនទី៥** :<br>**ពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ**<br>៥.១- អត្ថន័យនៃអាពាហ៍ពិពាហ៍<br>៥.២- ដំណើរវិវត្តអាពាហ៍ពិពាហ៍ខ្មែរ<br>៥.៣- ពិធីចែចូវ ពិធីកំជាប់ពាក្យ<br>៥.៤- ការរៀបចំពិធីមង្គលការខ្មែរបច្ចុប្បន្ន | **វិជ្ជាសម្បទា**<br>- កំណត់អត្ថន័យ អាពាហ៍ពិពាហ៍<br>- បង្ហាញពីដំណើរវិវត្ត និងរបៀបរៀបចំពិធីអាពាហ៍ពិពាហ៍ខ្មែរតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។<br>**បំណិនសម្បទា**<br>- អាចរៀបចំពិធីរៀបអាពាហ៍ពិពាហ៍បានទៅតាមលក្ខណៈខ្មែរ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីចូលរួម ការពារ ថែរក្សា និងអភិរក្សពិធីអាពាហ៍ពិពាហ៍ខ្មែរ។ | ៣ម៉ |
| **មេរៀនទី៦** : **គុណមាតាបិតា**<br>៦.១- និយមន័យ<br>៦.២- ការរក្សាគភ៌ និងការផ្តល់កំណើត<br>៦.៣- ការចិញ្ចឹមបីបាច់ថែរក្សាកូនរបស់មាតាបិតា<br>៦.៤- ការតបស្នង និងការដឹងគុណរបស់បុត្រធីតា<br>៦.៥- មាតាបិតាជាព្រហ្ម<br>៦.៦- មាតាបិតាជាបុព្វទេវា<br>៦.៧- មាតាបិតាជាបុព្វាចារ្យ<br>៦.៨- មាតាបិតាជាអាហុនេយ្យ | **វិជ្ជាសម្បទា**<br>- ដឹងពីទុក្ខលំបាករបស់មាតាក្នុងការថែរក្សាគភ៌ ការផ្តល់កំណើត និងការចិញ្ចឹមបីបាច់បុត្រធីតា។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់ភាពលំបាករបស់មាតាបិតាជាការតបស្នង សងគុណនិងធ្វើជាកូនល្អក្នុងគ្រួសារ។<br>**ចរិយាសម្បទា**<br>- ស្រឡាញ់ គោរព និងដឹងគុណមាតាបិតា។ | ៣ម៉ |
| **ជំពូកទី៤ : សង្គមយើង** | | |
| **មេរៀនទី១** : **មនសិការ**<br>១.១- និយមន័យ<br>១.២- ការបណ្តុះញាណ និងឆន្ទៈ<br>១.៣- មនសិការការងារ និងការទទួលខុសត្រូវ<br>១.៤- មនសិការ និងការស្រឡាញ់ជាតិកំណើត<br>១.៥- ជនគម្រូ ឬវីរជន | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ មនសិការ<br>- រៀបរាប់បានពីបញ្ញត្តិមនសិការ ញាណ និងឆន្ទៈ។<br>**បំណិនសម្បទា**<br>- បង្ហាញបានអំពីវិធីបណ្តុះមនសិការ ឆន្ទៈ និងញាណ។<br>**ចរិយាសម្បទា**<br>- មានស្មារតីគោរពស្រឡាញ់ ឆន្ទៈមនសិការ។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី២** : **អង្គការតុលាការកម្ពុជា**<br>២.១- និយមន័យ<br>២.២- រចនាសម្ព័ន្ធអង្គការតុលាការ<br>២.៣- តុលាការជំនាញ និងសមាសភាព<br>២.៤- សមត្ថកិច្ចអង្គការតុលាការ<br>២.៥- ដំណើរការប្រព្រឹត្តទៅអង្គការតុលាការ<br>២.៦- តួនាទី ភារកិច្ចតុលាការ<br>២.៧- សារៈសំខាន់នៃឯករាជ្យភាពតុលាការ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ អង្គការតុលាការ<br>- ពណ៌នាសមាសភាពអង្គការតុលាការជាន់ទាប និងជាន់ខ្ពស់ និងសមត្ថកិច្ចរបស់អង្គការតុលាការ។<br>**បំណិនសម្បទា**<br>- ស្វែងយល់ពីតួនាទី ភារកិច្ចរបស់តុលាការ<br>- កំណត់បានពីតួនាទី ភារកិច្ចតុលាការជំនាញ។<br>**ចរិយាសម្បទា**<br>- ចូលរួមនអនុវត្តច្បាប់បានត្រឹមត្រូវ និងមានស្មារតីទទួលខុសត្រូវលើអំពើរបស់ខ្លួន។ | ៣ម៉ |
| **មេរៀនទី៣** : **សមភាព និងវិសមភាព**<br>៣.១- និយមន័យ<br>៣.២- មូលហេតុនាំឱ្យមានវិសមភាព<br>៣.៣- គម្លាតរវាងអ្នកមាន និងអ្នកក្រ<br>៣.៤- ផលប៉ះពាល់នៃវិសមភាព<br>៣.៥- មធ្យោបាយក្នុងការកាត់បន្ថយវិសមភាព | **វិជ្ជាសម្បទា**<br>- បង្ហាញអំពីបញ្ញត្តិ សមភាព និងវិសមភាព<br>- រៀបរាប់បានអំពីកត្តាទាំងឡាយដែលនាំឱ្យមានវិសមភាពអំណាច វិសមភាពសេដ្ឋកិច្ចជម្លោះ ការរើសអើង និងការវិនិច្ឆ័យអវិជ្ជមាន។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីមូលហេតុដែលនាំឱ្យមានវិសមភាព។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីចូលរួមកាត់បន្ថយវិសមភាព និងលើកកម្ពស់សមភាព។ | ៣ម៉ |
| **មេរៀនទី៤** : **សន្តិភាព និងទំនាស់**<br>៤.១- និយមន័យ<br>៤.២- ប្រភេទនៃទំនាស់<br>៤.៣- មូលហេតុនៃទំនាស់<br>៤.៤- វិបាកនៃទំនាស់ និងការកសាងសន្តិភាព<br>៤.៥- សារៈសំខាន់នៃសន្តិភាព<br>៤.៦- ការលើកកម្ពស់ និងការការពារសុខុមាលភាពបុគ្គលនិងសមូហភាព<br>៤.៧- ទស្សនាទាននៃសន្តិភាព ការកសាងមតិរួម និងអហិង្សា | **វិជ្ជាសម្បទា**<br>- កំណត់ពីនិយមន័យ សន្តិភាព និងទំទាស់<br>- រៀបរាប់ប្រភពដែលនាំឱ្យកើតមានទំនាស់ និងសារៈសំខាន់នៃការកសាងសន្តិភាព។<br>**បំណិនសម្បទា**<br>- បង្ហាញទិដ្ឋភាពវិជ្ជមាន និងទិដ្ឋភាពអវិជ្ជមានរបស់ទំនាស់ និងសន្តិភាព<br>- ឆ្លុះបញ្ចាំងអំពីបទពិសោធនៃការយល់ឃើញរបស់មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីដោះស្រាយទំនាស់ដោយសន្តិវិធី និងប្រកាន់ខ្ជាប់ធម៌អហិង្សា។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៥ : សុខភាពផ្លូវចិត្ត**<br>៥.១- និយមន័យ<br>៥.២- មូលហេតុនៃជំងឺផ្លូវចិត្ត<br>៥.៣- ការតានតឹងចិត្ត<br>៥.៤- ប្រភេទជំងឺផ្លូវចិត្ត<br>៥.៥- វិធីព្យាបាលជំងឺផ្លូវចិត្ត<br>៥.៦- ស្ថានភាពសុខភាពផ្លូវចិត្តនៅកម្ពុជាបច្ចុប្បន្ន<br>៥.៧- ការអភិវឌ្ឍសេវាសុខភាពផ្លូវចិត្ត | **វិជ្ជាសម្បទា**<br>- បកស្រាយពីមូលហេតុនៃជំងឺផ្លូវចិត្ត<br>- កំណត់បានពីប្រភេទ រោគសញ្ញា និងវិធីព្យាបាលនៃជំងឺផ្លូវចិត្តដូចជា ជំងឺថប់បារម្ភ ជំងឺកាយវិបល្លាស ជំងឺធ្លាក់ទឹកចិត្ត ជំងឺបាក់ស្បាត។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីមូលហេតុ ប្រភេទ រោគសញ្ញា វិធីព្យាបាល ដំណោះស្រាយនៃជំងឺផ្លូវចិត្ត។<br>**ចរិយាសម្បទា**<br>- ចូលរួមដោះស្រាយជំងឺផ្លូវចិត្ត និងចៀសវាងមូលហេតុដែលនាំឱ្យមានជំងឺផ្លូវចិត្ត។ | ៣ម៉ |
| **មេរៀនទី៦ : គុណវិបត្តិនៃការផឹកសុរា និងជក់បារី**<br>៦.១- ចំណេះដឹងទូទៅអំពីសុរា និងបារី<br>៦.២- មូលហេតុនៃការផឹកសុរា និងការជក់បារី<br>៦.៣- ផលប៉ះពាល់នៃសុរា និងបារី<br>៦.៤- ស្ថានភាពផឹកសុរា និងជក់បារីនៅកម្ពុជាបច្ចុប្បន្ន<br>៦.៥- វិធីចៀសវាងការផឹកសុរា និងជក់បារី | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីគុណវិបត្តិនៃការផឹកសុរា និងជក់បារី<br>**បំណិនសម្បទា**<br>- បង្ហាញបានអំពីផលប៉ះពាល់និងដំណោះស្រាយនៃការផឹកសុរានិងជក់បារី ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីចៀសវាងការផឹកសុរា និងជក់បារី។ | ៣ម៉ |
| **មេរៀនទី៧ : ការស្រាវជ្រាវ**<br>៧.១- និយមន័យ<br>៧.២- សេចក្ដីផ្ដើមនៃការស្រាវជ្រាវ<br>៧.៣- ការរំលឹកទ្រឹស្ដី<br>៧.៤- វិធីសាស្ត្រស្រាវជ្រាវ<br>៧.៥- លទ្ធផលស្រាវជ្រាវ<br>៧.៦- សន្និដ្ឋាន ឬអនុសាសន៍ | **វិជ្ជាសម្បទា**<br>- កំណត់ពីនិយមន័យ ការស្រាវជ្រាវ<br>- រៀបរាប់បានពីដំណើរការស្រាវជ្រាវ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីដំណើរការ និងរបៀបនៃការស្រាវជ្រាវ។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីស្រឡាញ់ និងចូលចិត្តធ្វើការសិក្សាស្រាវជ្រាវ។ | ៤ម៉ |
| **មេរៀនទី៨ : ជំរឿននៅកម្ពុជា**<br>៨.១- ប្រវត្តិនៃការធ្វើជំរឿន<br>៨.២- មូលហេតុនៃការធ្វើជំរឿន<br>៨.៣- បញ្ហាប្រឈមក្នុងការធ្វើជំរឿន<br>៨.៤- សារៈសំខាន់នៃការធ្វើជំរឿន | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ជំរឿន ពណ៌នាប្រវត្តិ បញ្ហាប្រឈម និងសារៈសំខាន់ក្នុងការធ្វើជំរឿន។<br>**បំណិនសម្បទា**<br>- បង្ហាញពីមូលហេតុ និងសារៈសំខាន់នៃការធ្វើជំរឿន ដើម្បីវិភាគបញ្ហាកើតឡើង និងធ្វើ | ៣ម៉ |

| | | |
|---|---|---|
| | ផែនការកសាងសហគមន៍។<br>**ចរិយាសម្បទា**<br>- រក្សាឥរិយាបថវិជ្ជមាន និងការចូលរួមយ៉ាងសកម្មក្នុងផែនការនានាដើម្បីអភិវឌ្ឍសហគមន៍។ | |
| **មេរៀនទី៩ : ការប្រើប្រាស់ផ្លូវថ្នល់ និងច្បាប់ចរាចរណ៍**<br>៩.១- ការប្រើប្រាស់ផ្លូវថ្នល់<br>៩.២- ច្បាប់ចរាចរណ៍ផ្លូវគោក<br>៩.៣- សញ្ញាចរាចរណ៍<br>៩.៤- សិទ្ធិរបស់អ្នកប្រើប្រាស់ផ្លូវ<br>៩.៥- មូលហេតុដែលបង្កគ្រោះថ្នាក់ចរាចរណ៍<br>៩.៦- ផលប៉ះពាល់នៃគ្រោះថ្នាក់ចរាចរណ៍<br>៩.៧- វិធានការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានអំពីប្រភេទផ្លូវថ្នល់មូលហេតុនានា និងដំណោះស្រាយគ្រោះថ្នាក់ចរាចរណ៍<br>- ប្រាប់ពីសិទ្ធិរបស់អ្នកប្រើប្រាស់ផ្លូវថ្នល់។<br>**បំណិនសម្បទា**<br>- បកស្រាយពីមូលហេតុ និងអាចដោះស្រាយគ្រោះថ្នាក់ចរាចរណ៍ និងផលប៉ះពាល់។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីចូលរួមគោរពច្បាប់ចរាចរណ៍ផ្លូវគោក ចូលរួមផ្សព្វផ្សាយ និងលើកកម្ពស់ការគោរពច្បាប់ចរាចរណ៍។ | ៤ម៉ |

## ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១

- ថ្នាក់វិទ្យាសាស្ត្រសង្គម ១០៥ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍)(១សប្តាហ៍/៣ម៉)
- ថ្នាក់វិទ្យាសាស្ត្រ ៧០ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍)(១សប្តាហ៍/២ម៉)

ក្នុងចំណោមមេរៀនថ្នាក់ទី១១ទាំងបួនជំពូកត្រូវបង្រៀនថ្នាក់វិទ្យាសាស្ត្រក្នុងមួយមេរៀនចំនួន២ម៉ោង

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : តម្លៃមនុស្ស** | | |
| **មេរៀនទី១ : ស្គាល់ខ្លួនឯង**<br>១.១- បញ្ញត្តិនៃការស្គាល់ខ្លួនឯង<br>១.២- ភាពចាំបាច់នៃការស្គាល់ខ្លួនឯងដើម្បីក្លាយជាពលរដ្ឋពេញលេញ<br>១.៣- វិធីកសាងទំនុកចិត្តខ្លួនឯង | **វិជ្ជាសម្បទា**<br>- បង្ហាញពីអត្ថន័យនៃការស្គាល់ខ្លួនឯង និងការកសាងទំនុកចិត្តលើខ្លួនឯងដើម្បីក្លាយជាពលរដ្ឋពេញលេញ.<br>**បំណិនសម្បទា**<br>- កំណត់បានពីរបៀបនៃការអភិវឌ្ឍ និងការកសាងទំនុកចិត្តខ្លួនឯង.<br>**ចរិយាសម្បទា**<br>- រៀបចំខ្លួនជាមនុស្សប្រកាន់ខ្ជាប់នូវអាកប្បកិរិយាវិជ្ជមានចំពោះសង្គម. | ៣ម៉ |
| **មេរៀនទី២ : គុណភាពជីវិត**<br>២.១- និយមន័យ<br>២.២- ភាពចាំបាច់នៃគុណភាពជីវិត<br>២.៣- កត្តាជំរុញឱ្យសម្រេចបាននូវគុណភាពជីវិត<br>២.៤- កត្តារាំងស្ទះដល់គុណភាពជីវិត<br>២.៥- គុណភាពជីវិត និងអំពើពុករលួយ<br>២.៦- ការលើកកម្ពស់សុខុមាលភាពនៅក្នុងសហគមន៍ដើម្បីឱ្យមានគុណភាពជីវិត | **វិជ្ជាសម្បទា**<br>- កំណត់បានពីអត្ថន័យនៃគុណភាពជីវិត និងធាតុចាំបាច់របស់វា។<br>**បំណិនសម្បទា**<br>- បកស្រាយបានពីកត្តាជំរុញឱ្យសម្រេចបាននូវគុណភាពជីវិត និងកត្តារាំងស្ទះ.<br>**ចរិយាសម្បទា**<br>- បណ្តុះឥរិយាបថល្អក្នុងរស់នៅ ចេះស្វែងរកគុណភាព និងអត្ថន័យនៃជីវិត។ | ៣ម៉ |
| **មេរៀនទី៣ : តម្លៃនៃការអប់រំ**<br>៣.១- និយមន័យ<br>៣.២- តម្លៃអប់រំបែបទស្សនវិជ្ជា<br>៣.៣- តម្លៃគំនិត ស្មារតី និងតម្លៃកម្មសិទ្ធិបញ្ញា<br>៣.៤- តម្លៃសារពាង្គកាយ<br>៣.៥- សារៈសំខាន់នៃការអប់រំ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីតម្លៃបែបទស្សនវិជ្ជា តម្លៃគំនិត ស្មារតី តម្លៃកម្មសិទ្ធិបញ្ញា និងសារពាង្គកាយ។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់តម្លៃបែបទស្សនវិជ្ជា តម្លៃគំនិត ស្មារតី និងសារពាង្គកាយ ជាប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីឱ្យតម្លៃនៃការអប់រំឱ្យក្លាយជាមនុស្សល្អ។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤** : **ទស្សនវិជ្ជាមនុស្ស**<br>៤.១- និយមន័យ<br>៤.២- ទ្រឹស្តីផ្សេងៗ ស្តីពីទស្សនវិជ្ជាមនុស្ស<br>៤.៣- មនុស្ស និងសង្គម<br>៤.៤- មនុស្ស និងព្រះអាទិទេព<br>៤.៥- តម្លៃជនជាតិខ្មែរ<br>៤.៦- សារៈសំខាន់នៃការប្រើប្រាស់ទស្សនវិជ្ជា មនុស្ស | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ទស្សនវិជ្ជាមនុស្ស សារៈសំខាន់ និងតម្លៃជនជាតិខ្មែរ។<br>**បំណិនសម្បទា**<br>- បង្ហាញបានលក្ខណៈមនុស្ស ធម្មជាតិ អាទិទេពនិងតម្លៃជនជាតិខ្មែរ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រឡាញ់ខ្លួនឯង សង្គម និងពិភពលោកក្នុងនាមជនជាតិខ្មែរ។ | ៣ម៉ |
| **មេរៀនទី៥** : **អំពើហិង្សា និងធម៌អហិង្សា**<br>៥.១- និយមន័យ<br>៥.២- រូបភាពនៃអំពើហិង្សា និងធម៌អហិង្សា<br>៥.៣- ទស្សនៈមួយចំនួនស្តីពីធម៌អហិង្សា<br>៥.៤- ផលប៉ះពាល់ និងវិធីទប់ស្កាត់នៃអំពើហិង្សា<br>៥.៥- ផលប្រយោជន៍នៃការប្រតិបត្តិធម៌អហិង្សា | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីអត្ថន័យ ប្រភេទ និងមូលហេតុ នៃអំពើហិង្សា និងធម៌អហិង្សា<br>- រៀបរាប់បានពីផលប៉ះពាល់នៃអំពើហិង្សា និងវិធីទប់ស្កាត់។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីទស្សនៈដែលទាក់ទងនឹងធម៌ អហិង្សា និងអំពើហិង្សា។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីឱ្យប្រកាន់ខ្ជាប់នូវធម៌អហិង្សា និងចៀសវាងអំពើហិង្សា។ | ៣ម៉ |
| **មេរៀនទី៦** : **សច្ចធម៌ និងសុចរិតធម៌**<br>៦.១- និយមន័យ<br>៦.២- ទស្សនៈផ្សេងៗអំពីសច្ចធម៌ និងសុចរិតធម៌<br>៦.៣- ផលប៉ះពាល់នៃការមិនប្រតិបត្តិសច្ចធម៌ និងសុចរិតធម៌<br>៦.៤- សារៈសំខាន់នៃការប្រកាន់យកសច្ចធម៌ និងសុចរិតធម៌ក្នុងការរស់នៅ<br>៦.៥- ការប្រតិបត្តិសច្ចធម៌ និងសុចរិតធម៌ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ សច្ចធម៌ និងសុចរិតធម៌<br>- បង្ហាញពីទស្សនៈមួយចំនួនអំពីសច្ចធម៌ និងសុចរិតធម៌។<br>**បំណិនសម្បទា**<br>- វែកញែកពីសារៈសំខាន់នៃការប្រកាន់យក សច្ចធម៌ សុចរិតធម៌ ការប្រតិបត្តិសច្ចធម៌ និងសុចរិតធម៌។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រកាន់ខ្ជាប់នូវអំពើសុចរិតទៀង ត្រង់ក្នុងការរស់នៅ។ | ៤ម៉ |
| **មេរៀនទី៧** : **សិទ្ធិ និងព្រំដែនសេរីភាព**<br>៧.១- និយមន័យ<br>៧.២- ទស្សនៈ និងគោលការណ៍ស្តីពីសិទ្ធិ និងព្រំដែនសេរីភាព | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ សិទ្ធិ និងសេរីភាព<br>- ពណ៌នាអត្ថន័យនៃការប្រើប្រាស់សិទ្ធិ និងព្រំដែនសេរីភាព។ | ៤ម៉ |

| | | |
|---|---|---|
| ៧.៣- រូបភាពស្តីពីការប្រើប្រាស់សិទ្ធិ<br>និងព្រំដែនសេរីភាព<br>៧.៤- វិបាកនៃការប្រើប្រាស់សិទ្ធិ និងសេរីភាព | **បំណិនសម្បទា**<br>- ប្រើប្រាស់សិទ្ធិ និងសេរីភាព ដោយគោរពសិទ្ធិអ្នកដទៃ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតី ពលរដ្ឋស្គាល់ពីសិទ្ធិ និងព្រំដែនសេរីភាពក្នុងក្របខណ្ឌនៃច្បាប់។ | |
| **មេរៀនទី៨ : ការវិនិច្ឆ័យ**<br>៨.១- និយមន័យ<br>៨.២- លក្ខណវិនិច្ឆ័យក្នុងលំនាំនៃការអភិវឌ្ឍពុទ្ធិ<br>៨.៣- ការវិនិច្ឆ័យតាមបែបប្រធានវិស័យភាព<br>និងវត្ថុវិស័យភាព<br>៨.៤- ការវិនិច្ឆ័យត្រឹមត្រូវ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ការវិនិច្ឆ័យ<br>- ពណ៌នាអត្ថន័យនៃការវិនិច្ឆ័យ តាមបែបប្រធានវិស័យភាព និងវត្ថុវិស័យភាព បែបគតិ និងអគតិ និងការត្រិះរិះពិចារណាប្រកបដោយហេតុផល។<br>**បំណិនសម្បទា**<br>- វែកញែកឱ្យឃើញភាពខុសគ្នារវាងការវិនិច្ឆ័យតាមប្រធានវិស័យភាព វត្ថុវិស័យភាព និងការវិនិច្ឆ័យត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- បណ្តុះមនសិការក្នុងការពិចារណារកហេតុផលឱ្យបានច្បាស់លាស់មុននឹងវិនិច្ឆ័យអ្វីមួយ។ | ៣ម៉ |
| **មេរៀនទី៩ : ការអនុវត្តសិទ្ធិ និងការការពារ**<br>៩.១- និយមន័យ<br>៩.២- គោលការណ៍ទូទៅនៃការប្រើសិទ្ធិ<br>៩.៣- កិច្ចការពារខ្លួនពីការបំពានសិទ្ធិ<br>៩.៤- ការបង្ការ និងទប់ស្កាត់ការបំពានសិទ្ធិ<br>៩.៥- តួនាទីយុវជនក្នុងការចូលរួមបង្ការ<br>និងទប់ស្កាត់ការបំពានសិទ្ធិ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ការប្រើប្រាស់សិទ្ធិ និងកិច្ចការពារសិទ្ធិ<br>- បង្ហាញបានពីគោលការណ៍ទូទៅនៃការប្រើប្រាស់សិទ្ធិនិងការការពារសិទ្ធិ។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់សិទ្ធិការពារខ្លួនស្របច្បាប់ តួនាទីយុវជនក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការបំពានសិទ្ធិ។<br>**ចរិយាសម្បទាៈ**<br>- បណ្តុះស្មារតីគោរពសិទ្ធិ និងទប់ស្កាត់ការរំលោភសិទ្ធិ ខ្លួនឯង គ្រួសារ និងសង្គម។ | ៣ម៉ |
| **មេរៀនទី១០ : សីលធម៌ និងវិទ្យាសាស្ត្រ**<br>១០.១- និយមន័យ<br>១០.២- មនុស្សជាភាវៈមានសីលធម៌<br>១០.៣- ទំនាក់ទំនងសីលធម៌ និងវិទ្យាសាស្ត្រ<br>១០.៤- ផលវិបាករបស់វិទ្យាសាស្ត្រខ្វះសីលធម៌ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ សីលធម៌ និងវិទ្យាសាស្ត្រ<br>- បង្ហាញបានពីទំនាក់ទំនងសីលធម៌ និងវិទ្យាសាស្ត្រ។ | ៣ម៉ |

| | | |
|---|---|---|
| | **បំណិនសម្បទា**<br>- ប្រើប្រាស់សីលធម៌ និងវិទ្យាសាស្ត្របាន ត្រឹមត្រូវជាតម្លៃសម្រាប់សង្គម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីមនុស្សឱ្យប្រើប្រាស់វិទ្យាសាស្ត្រ ប្រកបដោយសីលធម៌។ | |
| **ជំពូកទី២ : ទំនាក់ទំនងល្អក្នុងសហគមន៍** | | |
| **មេរៀនទី១ : លទ្ធិប្រជាធិបតេយ្យ**<br>១.១- និយមន័យ<br>១.២- ធាតុសំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យ<br>១.៣. តួនាទី ភារកិច្ចគណបក្សនយោបាយ ក្នុងសង្គមប្រជាធិបតេយ្យ<br>១.៤- ការបោះឆ្នោតបែបលទ្ធិប្រជាធិបតេយ្យ<br>១.៥- ប្រព័ន្ធពហុបក្ស<br>១.៦- ការបែងចែកអំណាច<br>១.៧- សារៈសំខាន់នៃការអនុវត្តតាមបែបលទ្ធិ ប្រជាធិបតេយ្យ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ លទ្ធិប្រជាធិបតេយ្យ<br>- រៀបរាប់បានពីសិទ្ធិ សេរីភាព សមភាព នីតិរដ្ឋ សេរីភាពសារព័ត៌មាន ការបញ្ចេញមតិ ការជ្រើសរើសតំណាង<br>- ពណ៌នាបានអំពីគោលការណ៍សំខាន់ៗនៃ ដំណើរការលទ្ធិប្រជាធិបតេយ្យ និងការបោះ ឆ្នោត។<br>**បំណិនសម្បទា**<br>- បង្ហាញពីសារៈសំខាន់ និងគោលការណ៍នៃ លទ្ធិប្រជាធិបតេយ្យ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីអនុវត្តលទ្ធិប្រជាធិបតេយ្យនៅក្នុង ថ្នាក់រៀន និងសង្គម។ | ៣ម៉ |
| **មេរៀនទី២ : តម្លាភាព សមភាព និង សមធម៌**<br>២.១- និយមន័យ<br>២.២- ទ្រឹស្តីផ្សេងៗស្តីពីតម្លាភាព សមភាព និងសមធម៌<br>២.៣- ទំនាក់ទំនងតម្លាភាព សមភាព  សមធម៌<br>២.៤- រូបភាព និងសារៈសំខាន់នៃការប្រតិបត្តិ តម្លាភាព សមភាព  និងសមធម៌ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ តម្លាភាព សមភាព និងសមធម៌<br>- ពន្យល់ពីសារៈសំខាន់នៃការប្រតិបត្តិដោយ តម្លាភាព សមភាព និងសមធម៌។<br>**បំណិនសម្បទា**<br>- បង្ហាញទស្សនៈ និងទំនាក់ទំនងស្តីពីតម្លាភាព សមភាព សមធម៌។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីប្រតិបត្តិប្រកបដោយតម្លាភាព សមភាព សមធម៌ក្នុងការងារ និងការរស់នៅ។ | ៥ម៉ |
| **មេរៀនទី៣ : សាមគ្គីធម៌**<br>៣.១- និយមន័យ<br>៣.២- រូបភាពសាមគ្គីធម៌<br>៣.៣- បច្ច័យនាំឱ្យមានសាមគ្គីធម៌ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ សាមគ្គីធម៌<br>- រៀបរាប់ពីមូលហេតុនាំឱ្យកើតមានសាមគ្គីធម៌ | ៣ម៉ |

| | | |
|---|---|---|
| ៣.៤- ផលនៃការសម្រេចបានសាមគ្គីធម៌<br>៣.៥- ការធ្វើសេចក្តីសម្រេចចិត្តផ្នែកនយោបាយ និងការចូលរួមរបស់ពលរដ្ឋដោយសាមគ្គីធម៌ | **បំណិនសម្បទា**<br>- បង្ហាញពីសារប្រយោជន៍នៃសាមគ្គីធម៌ និងចេះដោះស្រាយបញ្ហា។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីរួបរួមគ្នា និងមានសាមគ្គីធម៌។ | |
| **មេរៀនទី៤** : **តួនាទីពលរដ្ឋក្នុងសហគមន៍**<br>៤.១- តួនាទីពលរដ្ឋក្នុងសហគមន៍<br>៤.២- តួនាទីក្នុងវិស័យសេដ្ឋកិច្ច និងការសន្សំប្រាក់នៅតាមសហគមន៍<br>៤.៣- តួនាទីក្នុងវិស័យសង្គមកិច្ច និងបរិស្ថាន<br>៤.៤- តួនាទីក្នុងវិស័យវប្បធម៌ និងទេសចរណ៍<br>៤.៥- តួនាទីក្នុងវិស័យសន្តិសុខសង្គម<br>៤.៦- ការចូលរួមសកម្មភាពសម្រាប់យុត្តិធម៌សង្គម | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីតួនាទីប្រជាពលរដ្ឋនៅក្នុងសហគមន៍ សង្គម-វប្បធម៌ សង្គមកិច្ច នយោបាយ និងយុត្តិធម៌សង្គម។<br>**បំណិនសម្បទា**<br>- បង្ហាញពីអ្វីដែលពលរដ្ឋត្រូវធ្វើ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍ និងការពារសន្តិសុខក្នុងមូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ។<br>**ចរិយាសម្បទា**<br>- មានស្មារតីរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ជាតិ និងអន្តរជាតិ។ | ៣ម៉ |
| **មេរៀនទី៥** : **សិល្បៈនៃការតស៊ូមតិ**<br>៥.១- និយមន័យ<br>៥.២- ប្រភេទនៃការតស៊ូមតិ<br>៥.៣- ភាពចាំបាច់ និងវិធីសមស្របនៃការតស៊ូមតិ<br>៥.៤- សីលធម៌នៃការតស៊ូមតិ<br>៥.៥- ការពិភាក្សា និងគោលការណ៍បញ្ចេញមតិ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ការតស៊ូមតិ<br>- ពណ៌នាពីអត្ថន័យ ប្រភេទនៃការតស៊ូមតិ និងគោលការណ៍បញ្ចេញមតិ។<br>**បំណិនសម្បទា៖**<br>- កំណត់បានពីភាពចាំបាច់ និងវិធីសមស្របនៃការតស៊ូមតិ។<br>**ចរិយាសម្បទា៖**<br>- មានស្មារតីចូលរួមតស៊ូមតិ ដើម្បីផល<br>- ប្រយោជន៍បុគ្គល សហគមន៍ និងសង្គម។ | ៤ម៉ |
| **មេរៀនទី៦** : **គណបក្សនយោបាយ**<br>៦.១- និយមន័យ<br>៦.២- ច្បាប់ស្តីពីគណបក្សនយោបាយ<br>៦.៣- ដើមកំណើតគណបក្សនយោបាយ<br>៦.៤- មុខងារគណបក្សនយោបាយ<br>៦.៥- រចនាសម្ព័ន្ធគណបក្សនយោបាយ<br>៦.៦- គណបក្សនយោបាយ និងអំណាច<br>៦.៧- ប្រព័ន្ធគណបក្សនយោបាយ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ គណបក្សនយោបាយ<br>- ពណ៌នាប្រភេទផ្សេងៗនៃប្រព័ន្ធគណបក្សនយោបាយ ការបង្កើត តួនាទី រចនាសម្ព័ន្ធ និងអំណាចគណបក្សនយោបាយ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីប្រព័ន្ធគណបក្សនយោបាយ តួនាទី ការបង្កើតបក្សនយោបាយនិង អំណាច។ | ៣ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- ចូលរួមក្នុងគណបក្សនយោបាយណាមួយតាមជំរើសរបស់ខ្លួន។ | |
| **មេរៀនទី៧** : **ការឈរឈ្មោះនិងការបោះឆ្នោត**<br>៧.១- ការបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោត<br>៧.២- សិទ្ធិបោះឆ្នោត និងការឈរឈ្មោះបោះឆ្នោត<br>៧.៣- ការចុះឈ្មោះ និងដំណើរការបោះឆ្នោត<br>៧.៤- ការបោះឆ្នោតសកល និងអសកល<br>៧.៥- សារៈសំខាន់នៃការបោះឆ្នោត | **វិជ្ជាសម្បទា**<br>- បង្ហាញពីដំណើរការបោះឆ្នោត ការឈរឈ្មោះបោះឆ្នោតនិងសិទ្ធិនៃការបោះឆ្នោតនៅកម្ពុជា។<br>**បំណិនសម្បទា**<br>- បង្ហាញសិទ្ធិ តួនាទី ការទទួលខុសត្រូវរបស់ពលរដ្ឋក្នុងការចូលរួមបោះឆ្នោត<br>- វែកញែកភាពខុសគ្នារវាងការបោះឆ្នោតសកលនិងអសកល។<br>**ចរិយាសម្បទា**<br>- ចូលរួមអនុវត្តសិទ្ធិបោះឆ្នោតក្នុងនាមជាពលរដ្ឋល្អ។ | ៣ម៉ |
| **មេរៀនទី៨** : **រដ្ឋបាលសាធារណៈ**<br>៨.១- និយមន័យ<br>៨.២- ប្រវត្តិនៃការកកើតរដ្ឋបាលសាធារណៈ<br>៨.៣- មុខងាររដ្ឋបាល និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល<br>៨.៤- អំណាចរដ្ឋបាលសាធារណៈ<br>៨.៥- អត្ថប្រយោជន៍ និងគុណវិបត្តិនៃការមិនប្រតិបត្តិរដ្ឋបាលសាធារណៈក្នុងសង្គមខ្មែរ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ រដ្ឋបាលសាធារណៈ<br>- ពណ៌នាពីប្រវត្តិនៃការកកើត មុខងារប្រព័ន្ធគ្រប់គ្រង និងអំណាចរដ្ឋបាលសាធារណៈ។<br>**បំណិនសម្បទា**<br>- ប្រាប់ពីអត្ថប្រយោជន៍ និងគុណវិបត្តិនៃការមិនប្រតិបត្តិរដ្ឋបាលសាធារណៈក្នុងសង្គមខ្មែរ<br>**ចរិយាសម្បទា**<br>- ចូលរួមគោរពច្បាប់និងបទបញ្ជាផ្សេងៗរបស់សង្គម។ | ៣ម៉ |
| **មេរៀនទី៩** : **ទ្រព្យសម្បត្តិសាធារណៈនិងទ្រព្យសម្បត្តិឯកជន**<br>៩.១- ទ្រព្យសម្បត្តិសាធារណៈ<br>៩.២- ទ្រព្យសម្បត្តិឯកជន<br>៩.៣- ការផ្ទេរ និងការកាន់កាប់ចលនវត្ថុ និងអចលនវត្ថុ<br>៩.៤- ការរំលោភបំពានទ្រព្យសម្បត្តិសាធារណៈ និងឯកជន<br>៩.៥- មនសិការថែរក្សាទ្រព្យសម្បត្តិសាធារណៈ | **វិជ្ជាសម្បទា**<br>- កំណត់បានពីទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន និងរបៀបប្រើប្រាស់<br>- បង្ហាញបានពីការរំលោភបំពានលើទ្រព្យសម្បត្តិសាធារណៈនិងទ្រព្យសម្បត្តិ ឯកជន។<br>**បំណិនសម្បទា**<br>- បង្ហាញពីភាពខុសគ្នារវាងទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជន។<br>**ចរិយាសម្បទា**<br>- ថែរក្សាទ្រព្យសម្បត្តិឯកជន និងទ្រព្យសម្បត្តិសាធាណបានត្រឹមត្រូវតាមគោលការណ៍ច្បាប់។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី១០** :<br>**សិទ្ធិជនជាតិផ្សេងៗនៅកម្ពុជា**<br>១០.១- វប្បធម៌នៃជនជាតិភាគតិចនៅកម្ពុជា<br>១០.២- ក្រុមជនជាតិផ្សេងៗ និងវប្បធម៌<br>១០.៣- សិទ្ធិរបស់ជនជាតិភាគតិច<br>១០.៤- តម្រូវការរបស់ជនជាតិ និងចម្លើយតបរបស់រាជរដ្ឋាភិបាល<br>១០.៥- ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សសម្រា ប់ទាំងអស់គ្នា | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីអត្តសញ្ញាណវប្បធម៌របស់ជនជាតិភាគតិច និងជនជាតិផ្សេងៗនៅកម្ពុជា។<br>**បំណិនសម្បទា**<br>- បង្ហាញពីសិទ្ធិ និងតម្រូវការរបស់ជនជាតិផ្សេងៗ<br>- ពិភាក្សាពីសិទ្ធិ និងតម្រូវការរបស់ជនជាតិភាគតិចនៅក្នុងប្រទេស និងគោរព លក្ខណៈពិសេសរបស់គេក្នុងសង្គម។<br>**ចរិយាសម្បទា**<br>- គោរពស្រឡាញ់ជនជាតិភាគតិចក្នុងនាមជាមនុស្សដូចគ្នា គ្មានការរើសអើង។ | ៣ម៉ |
| **ជំពូកទី៣ : វប្បធម៌ សាសនា និងការអប់រំ** | | |
| **មេរៀនទី១** : **ប្រវត្តិសាសនាក្នុងពិភពលោក**<br>១.១- និយមន័យ<br>១.២- កំណើតមនុស្ស និងជំនឿ<br>១.៣- សាសនាធំៗក្នុងពិភពលោក<br>១.៤- ការគោរពពិពិធភាពសាសនា | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ សាសនា<br>- ពណ៌នាពីកំណើតជំនឿ និងសាសនា។<br>**បំណិនសម្បទា**<br>- បង្ហាញពីសាសនាធំៗក្នុងពិភពលោក។<br>**ចរិយាសម្បទា**<br>- គោរព ស្រឡាញ់ និងឱ្យតម្លៃចំពោះសាសនា។ | ៣ម៉ |
| **មេរៀនទី២** : **ព្រហ្មញ្ញ-ហិណ្ឌូសាសនា**<br>២.១- ដើមកំណើត<br>២.២- គម្ពីរវេទ<br>២.៣- ការបែងចែកវណ្ណៈសង្គម<br>២.៤- មគ្គៈ (យោគៈ) ទៅកាន់គោលបំណង<br>២.៥- ដំណាក់កាលជីវិត<br>២.៦- តម្រូវការ និងគោលបំណងហិណ្ឌូនិយម<br>២.៧- ការប្រតិបត្តិ និងពិធីបែបសាសនាហិណ្ឌូ<br>២.៨- ឥទ្ធិពលសាសនាហិណ្ឌូ មកលើសង្គមខ្មែរ<br>២.៩- អត្ថប្រយោជន៍របស់សាសនាហិណ្ឌូ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីប្រវត្តិកំណើតសាសនា ការប្រតិបត្តិ និងពិធីនានារបស់សាសនាមកលើសង្គមខ្មែរ។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់ពិធីសាសនាហិណ្ឌូដើម្បីជាប្រយោជន៍។<br>**ចរិយាសម្បទា**<br>- បណ្តុះឥរិយាបថវិជ្ជមានចំពោះសាសនាហិណ្ឌូ។ | ៣ម៉ |
| **មេរៀនទី៣** : **ព្រះពុទ្ធសាសនា**<br>៣.១- ពុទ្ធប្រវត្តិសង្ខេប<br>៣.២- ទ្រឹស្តីកម្មផល<br>៣.៣- ទ្រឹស្តីបដិច្ចសមុប្បាទ<br>៣.៤- អរិយសច្ចៈ<br>៣.៥- មជ្ឈិមបដិបទា | **វិជ្ជាសម្បទា**<br>- ពណ៌នាពីទ្រឹស្តី ដែលប្រតិបត្តិក្នុងព្រះពុទ្ធសាសនាមហាយាន និងពុទ្ធសាសនាថេរវាទ (ហិនយាន)។ | ៣ម៉ |

| | | |
|---|---|---|
| ៣.៦- ការប្រតិបត្តិទស្សនវិជ្ជាព្រះពុទ្ធសាសនា<br>នៅក្នុងសង្គមខ្មែរបច្ចុប្បន្ន | **បំណិនសម្បទា**<br>- បង្ហាញពីការគោរព និងប្រតិបត្តិសាសនា បានត្រឹមត្រូវ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរព និងឱ្យតម្លៃព្រះពុទ្ធ សាសនា។ | |
| **មេរៀនទី៤** : **សាសនាគ្រិស្ត**<br>៤.១- ដើមកំណើតព្រះយេស៊ូគ្រិស្ត<br>៤.២- អត្ថិភាពសាសនាគ្រិស្តក្នុងសង្គមខ្មែរ<br>៤.៣- ពិធីបំបួស និងអត្ថន័យ<br>៤.៤- និកាយក្នុងគ្រិស្តសាសនា<br>៤.៥- អត្ថប្រយោជន៍គ្រិស្តសាសនាក្នុងសង្គមខ្មែរ<br>៤.៦- ទស្សនវិជ្ជាគ្រិស្តសាសនា | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីដើមកំណើត ពិធីបំបួស អត្ថន័យ អត្ថប្រយោជន៍ និងទ្រឹស្តីទស្សនវិជ្ជាក្នុង សាសនាគ្រិស្ត។<br>**បំណិនសម្បទា**<br>- ស្វែងយល់ពីដើមកំណើត ពិធីបំបួស អត្ថន័យ អត្ថប្រយោជន៍ និងទ្រឹស្តីទស្សនវិជ្ជាក្នុង សាសនាគ្រិស្ត។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរព និងមិនរើសអើងសាសនា គ្រិស្ត។ | ៣ម៉ |
| **មេរៀនទី៥** : **សាសនាឥស្លាម**<br>៥.១- ដើមកំណើតសាសនាឥស្លាម<br>៥.២- អត្ថិភាពសាសនាឥស្លាមក្នុងសង្គមខ្មែរ<br>៥.៣- និកាយសាសនាឥស្លាម<br>៥.៤- អត្ថប្រយោជន៍ សាសនាឥស្លាមក្នុងសង្គមខ្មែរ<br>៥.៥- ទស្សនវិជ្ជាសាសនាឥស្លាម | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីដើមកំណើត អត្ថន័យ អត្ថប្រយោជន៍ និងទ្រឹស្តីទស្សនវិជ្ជាក្នុងសាសនាឥស្លាម។<br>**បំណិនសម្បទា**<br>- ដកស្រង់ពីដើមកំណើត អត្ថន័យ អត្ថប្រយោជន៍ និងទ្រឹស្តីទស្សនវិជ្ជាក្នុងសាសនា ឥស្លាម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរព និងមិនរើសអើងសាសនា ឥស្លាម។ | ៣ម៉ |
| **មេរៀនទី៦** : **សាសនាតាវ និងស៊ីនតូ**<br>៦.១- ប្រវត្តិសាសនាតាវ និងស៊ីនតូ<br>៦.២- ការប្រតិបត្តិសាសនាតាវ និងស៊ីនតូ<br>៥.៣- អត្ថប្រយោជន៍សាសនាតាវ និងស៊ីនតូ<br>៦.៤- ទស្សនវិជ្ជារបស់សាសនាតាវ និងស៊ីនតូ | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីប្រវត្តិសាសនាតាវ និងស៊ីនតូ<br>- ពន្យល់ពីការប្រតិបត្តិ និងការទូន្មានរបស់ សាសនាតាវ និងស៊ីនតូ។<br>**បំណិនសម្បទា**<br>- ស្វែងយល់ពីទស្សនវិជ្ជារបស់សាសនាតាវ និង ស៊ីនតូ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរព និងមិនរើសអើងសាសនា តាវ និងស៊ីនតូ។ | ៣ម៉ |

| ជំពូកទី៤ : សង្គមយើង | | |
|---|---|---|
| **មេរៀនទី១ : មនុស្ស និងបរិស្ថាន**<br>១.១- និយមន័យ<br>១.២- ទំនាក់ទំនងមនុស្ស និងបរិស្ថាន<br>១.៣- បរិស្ថាន និងធនធានធម្មជាតិ<br>១.៤- ច្បាប់ និងគោលនយោបាយ ស្តីពីបរិស្ថាន<br>១.៥- មូលហេតុ និងផលប៉ះពាល់នៃការបំផ្លាញ បរិស្ថាន<br>១.៦- ការអភិវឌ្ឍប្រកបដោយនិរន្តរភាព | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ បរិស្ថាន<br>- បង្ហាញពីទំនាក់ទំនងបរិស្ថានជាមួយមនុស្ស មូលហេតុ និងផលប៉ះពាល់នៃការបំផ្លាញ បរិស្ថាន។<br>**បំណិនសម្បទា**<br>- បង្ហាញពីច្បាប់ គោលនយោបាយស្តីពីបរិស្ថាន និងគុណវិបត្តិនៃការបំផ្លាញបរិស្ថាន។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីការពារ ស្រឡាញ់បរិស្ថាន ធម្មជាតិ។ | ៣ម៉ |
| **មេរៀនទី២** :<br>**ការបម្រើការងារក្នុងវិស័យឯកជន**<br>២.១- ច្បាប់ស្តីពីការងារ<br>២.២- លក្ខខណ្ឌទូទៅនៃការងារ<br>២.៣- ការហ្វឹកហ្វឺនកូនជាង<br>២.៤- កិច្ចសន្យាការងារ<br>២.៥- លក្ខខណ្ឌនៃការចូលបម្រើការងារ<br>២.៦. ហានិភ័យការងារ<br>២.៧- ជម្លោះ និងការដោះស្រាយវិវាទការងារ | **វិជ្ជាសម្បទា**<br>- បង្ហាញបានពីលក្ខខណ្ឌទូទៅនៃការងារ ការហ្វឹកហ្វឺនកូនជាង កិច្ចសន្យាការងារ លក្ខខណ្ឌនៃការចូលបម្រើការងារ ហានិភ័យ ការងារ ជម្លោះនិងការដោះស្រាយវិវាទ ការងារ។<br>**បំណិនសម្បទា**<br>- វែកញែកពីលក្ខខណ្ឌ និងហានិភ័យការងារ ដែលច្បាប់បានកំណត់។<br>**ចរិយាសម្បទា**<br>- បណ្តុះមនសិការវិជ្ជាជីវៈ និងគោរពច្បាប់ ការងារ។ | ៣ម៉ |
| **មេរៀនទី៣ : ការជ្រើសរើសវិជ្ជាជីវៈ**<br>៣.១- និយមន័យ<br>៣.២- ការតម្រង់ទិសវិជ្ជាជីវៈ<br>៣.៣- លក្ខខណ្ឌក្នុងការជ្រើសរើសមុខជំនាញ<br>៣.៤- ផលប៉ះពាល់នៃការជ្រើសរើសជំនាញ វិជ្ជាជីវៈមិនបានត្រឹមត្រូវ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ វិជ្ជាជីវៈ<br>- បង្ហាញពីការជ្រើសរើសមុខជំនាញបានត្រឹមត្រូវ ដោយគិតពីលទ្ធភាព សមត្ថភាព ចំណង់ ចំណូលចិត្ត និងតម្រូវការទីផ្សារការងារ។<br>**បំណិនសម្បទា**<br>- បង្ហាញពីសារៈសំខាន់នៃការតម្រង់ទិសវិជ្ជាជីវៈ រួមទាំងជំនាញក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុ។<br>**ចរិយាសម្បទា**<br>- មានទំនួលខុសត្រូវលើការជ្រើសរើសមុខជំនា | ៣ម៉ |

| | | |
|---|---|---|
| | ញវិជ្ជាជីវៈស្របតាមទីផ្សារការងារ ចំណង់<br>ចំណូលចិត្ត និងសមត្ថភាព។ | |
| **មេរៀនទី៤** : **ក្រមសីលធម៌វិជ្ជាជីវៈ**<br>៤.១- និយមន័យ<br>៤.២- សារៈសំខាន់នៃក្រមសីលធម៌វិជ្ជាជីវៈ<br>៤.៣- ផលវិបាកនៃការខ្វះក្រមសីលធម៌វិជ្ជាជីវៈ<br>៤.៤- ការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ<br>និងការទទួលខុសត្រូវចំពោះសង្គម | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ក្រមសីលធម៌វិជ្ជាជីវៈ<br>- ពណ៌នាពីសារៈសំខាន់នៃក្រមសីលធម៌វិជ្ជាជីវៈ<br>និងផលវិបាកនៃការខ្វះក្រមសីលធម៌វិជ្ជាជីវៈ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីការប្រតិបត្តិក្រមសីលធម៌វិជ្ជាជីវៈ<br>និងការទទួលខុសត្រូវចំពោះសង្គម។<br>**ចរិយាសម្បទា**<br>- មានស្មារតីគោរព និងឱ្យតម្លៃក្រមសីលធម៌<br>វិជ្ជាជីវៈ។ | ៣ម៉ |
| **មេរៀនទី៥** : **ការគ្រប់គ្រងហានិភ័យ**<br>៥.១- និយមន័យ<br>៥.២- ប្រភេទនៃហានិភ័យ រួមទាំងហានិភ័យ<br>អាជីវកម្មហិរញ្ញវត្ថុ<br>៥.៣- សារៈសំខាន់នៃការគ្រប់គ្រងហានិភ័យ<br>ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ<br>៥.៤- យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ហានិភ័យ<br>- បង្ហាញពីសារៈសំខាន់ និងអត្ថប្រយោជន៍<br>នៃការគ្រងគ្រងហានិភ័យហិរញ្ញវត្ថុ។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់សមត្ថភាព របៀប ទេពកោសល្យ<br>ក្នុងការគ្រប់គ្រងហានិភ័យដោយខ្លួនឯង។<br>**ចរិយាសម្បទា**<br>- ចូលរួមការពារហានិភ័យហិរញ្ញវត្ថុ។ | ២ម៉ |
| **មេរៀនទី៦** : **ទ្រព្យសម្បត្តិសាធារណៈ**<br>៦.១- និយមន័យ<br>៦.២- ប្រភេទនៃទ្រព្យសម្បតិសាធារណៈ<br>៦.៣- ពលរដ្ឋ និងទ្រព្យសម្បតិសាធារណៈ<br>៦.៤- ផលប៉ះពាល់នៃការបង្លិចបំផ្លាញទ្រព្យសម្បត្តិ<br>សាធារណៈ<br>៦.៥- កាតព្វកិច្ចពលរដ្ឋក្នុងការថែរក្សា<br>ទ្រព្យសម្បតិសាធារណៈ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ទ្រព្យសម្បត្តិសាធារណៈ<br>- ពណ៌នាបានពីប្រភេទទ្រព្យសម្បត្តិ<br>សាធារណៈ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីប្រភេទនៃទ្រព្យសម្បត្តិ<br>សាធារណៈ ផលប៉ះពាល់នៃការបំផ្លាញ<br>ទ្រព្យសម្បត្តិសាធារណៈ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីថែរក្សាទ្រព្យសម្បត្តិសាធារណៈ។ | ៣ម៉ |
| **មេរៀនទី៧** : **អាពាហ៍ពិពាហ៍ និងគ្រួសារ**<br>៧.១- លក្ខខណ្ឌក្នុងការរៀបអាពាហ៍ពិពាហ៍<br>៧.២- សិទ្ធិ ករណីយកិច្ចសហព័ទ្ធ<br>៧.៣- គោលការណ៍ឯកពន្ធភាព<br>៧.៤- ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស | **វិជ្ជាសម្បទា**<br>- ពណ៌នាលក្ខខណ្ឌក្នុងការរៀបអាពាហ៍ពិពាហ៍<br>សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធ<br>- ពណ៌នាការរៀបអាពាហ៍ពិពាហ៍ជាមួយជន<br>បរទេស | ៣ម៉ |

| | | |
|---|---|---|
| ៧.៥- ករណីយកិច្ចរបស់ឪពុកម្តាយ និងកូន<br>៧.៦- ការលែងលះ ការបែងចែកទ្រព្យសម្បត្តិ និងការគ្រប់គ្រងកូន | - បង្ហាញពីនីតិវិធី និងអានុភាពនៃការលែងលះ។<br>**បំណិនសម្បទា**<br>- ផែកញែកបានពីសិទ្ធិ និងករណីកិច្ចក្នុងគ្រួសារ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីទទួលខុសត្រូវក្នុងគ្រួសារ។ | |
| **មេរៀនទី៨ : គុណវិបត្តិនៃការប្រើប្រាស់គ្រឿងញៀន**<br>៨.១- និយមន័យ<br>៨.២- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន<br>៨.៣- មូលហេតុនៃការប្រើប្រាស់គ្រឿញៀន<br>៨.៤- គុណវិបត្តិនៃការប្រើប្រាស់គ្រឿងញៀន<br>៨.៥- វិធីសំខាន់ៗក្នុងការចៀសវាងការប្រើប្រាស់គ្រឿងញៀន | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ គ្រឿងញៀន<br>- រៀបរាប់ពីមូលហេតុ គុណវិបត្តិការប្រើប្រាស់ និង វិធីសំខាន់ៗក្នុងការចៀសវាងការប្រើប្រាស់គ្រឿងញៀន។<br>**បំណិនសម្បទា**<br>- បង្ហាញពីការផ្តន្ទាទោសចំពោះអ្នកប្រើប្រាស់ និងចែកចាយគ្រឿងញៀន។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីថែរក្សាសុខភាព និងប្រយុទ្ធប្រឆាំងការប្រើប្រាស់គ្រឿងញៀន។ | ៣ម៉ |

### ៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២

**- ថ្នាក់វិទ្យាសាស្ត្រសង្គម ១០៥ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១/សប្តាហ៍ ៣ម៉)**

**- ថ្នាក់វិទ្យាសាស្ត្រ ៧០ម៉ោង (១ឆ្នាំ/៣៥សប្តាហ៍) (១/សប្តាហ៍ ២ម៉)**

ក្នុងចំណោមមេរៀនថ្នាក់ទី១២ទាំងបួនជំពូកត្រូវបង្រៀនថ្នាក់វិទ្យាសាស្ត្រក្នុងមួយមេរៀនចំនួន២ម៉ោង

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង |
|---|---|---|
| **ជំពូកទី១ : តម្លៃមនុស្ស** | | |
| **មេរៀនទី១ : បញ្ញា**<br>១.១- បញ្ញត្តិបញ្ញា<br>១.២- សភាវគតិ និងបញ្ញា<br>១.៣- បញ្ញាសត្វ និងបញ្ញាមនុស្ស<br>១.៤- វាស់បញ្ញា<br>១.៥- បញ្ញាទូទៅ និងសម្បទាឯកទេស<br>១.៦- តម្លៃកម្មសិទ្ធិបញ្ញា | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ បញ្ញា<br>- ពណ៌នាបញ្ញាទូទៅ និងសម្បទានីមួយៗ។<br>**បំណិនសម្បទា**<br>- បង្ហាញឱ្យឃើញលក្ខណៈខុសគ្នារវាង បញ្ញាមនុស្ស និងបញ្ញាសត្វ (ល.កូល័រ) ធ្វើពិសោធបង្ហាញអំពីការរកលទ្ធផល បញ្ញា។<br>**ចរិយាសម្បទា**<br>- យកចិត្តទុកដាក់ និងឱ្យតម្លៃបញ្ញា និងអ្វី ដែលមនុស្សរកឃើញថ្មីៗ។ | ៣ម៉ |
| **មេរៀនទី២ : តម្លៃនៃការបង្កើតថ្មី និងកិច្ចការពារ**<br>២.១- ឥន្ទ្រីយារម្មណ៍<br>២.២- រូបភាព<br>២.៣- មនោគតិបង្កើត<br>២.៤- កត្តាទាំងឡាយនៃការបង្កើតថ្មី<br>២.៥- ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រ ម៉ូដែលមានអត្ថប្រយោជន៍ និងគំនូឧស្សាហកម្ម<br>២.៦- លក្ខខណ្ឌចាត់ទុកជាការបង្កើតថ្មី<br>២.៧- ស្នាដៃ និងការការពារ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីនិយមន័យនៃ ឥន្ទ្រីយារម្មណ៍ រូបភាព មនោគតិបង្កើត និងសតិនៃ ការបង្កើតថ្មី។<br>**បំណិនសម្បទា**<br>- បង្ហាញកត្តាទាំងឡាយដែលនាំឱ្យមាន ការបង្កើតថ្មី និងលក្ខខណ្ឌរបស់វា។<br>**ចរិយាសម្បទា**<br>- បណ្តុះគំនិតច្នៃប្រឌិត និងទទួលស្គាល់ ស្នាដៃនៃបង្កើតថ្មី ។ | ៣ម៉ |
| **មេរៀនទី៣ : លក្ខិចទ្ធនៅនៃគំនិត**<br>៣.១- វិចារទូទៅ (បញ្ញត្តិ វិនិច្ឆ័យ និងវិចារ)<br>៣.២- អនុមានញែក អនុមានរួម<br>៣.៣- វិភាគ និងសំយោគ<br>៣.៤- អព្ភន្តរញាណ<br>៣.៥- ទំនាក់ទំនងរវាងអព្ភន្តរញាណ និងវិចារ<br>៣.៦- ពុទ្ធិ និងប្រភេទពុទ្ធិ | **វិជ្ជាសម្បទា**<br>- ពណ៌នាអំពីអត្ថន័យនៃវិចារទូទៅ ពុទ្ធិ អព្ភន្តរញាណ និងវិចារ។<br>**បំណិនសម្បទា**<br>- បង្ហាញពីទំនាក់ទំនងរវាងអព្ភន្តរញាណ និងវិចារ វិភាគ និងសំយោគ។<br>**ចរិយាសម្បទា**<br>- ចេះវិភាគរកហេតុផលច្បាស់លាស់មុននឹង ធ្វើការសម្រេចប្រកបដោយពុទ្ធិ។ | ៤ម៉ |

| | | |
|---|---|---|
| **មេរៀនទី៤** : **ទំនាក់ទំនងនៃធម្មជាតិមនុស្ស**<br>៤.១- និយមន័យ<br>៤.២- ប្រភេទនៃទំនាក់ទំនង<br>៤.៣- សារៈសំខាន់នៃទំនាក់ទំនង<br>៤.៤- ការបណ្តុះទំនាក់ទំនង | **វិជ្ជាសម្បទា**<br>- កំណត់ពីនិយមន័យទំនាក់ទំនង និងប្រភេទទំនាក់ទំនង (ទំនាក់ទំនងសរីរាង្គ ផ្ទាល់ខ្លួន អន្តរបុគ្គល ឧត្តមគតិ និងសង្គម)។<br>**បំណិនសម្បទា**<br>- បកស្រាយពីសារៈសំខាន់ និងការបណ្តុះទំនាក់ទំនង។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីឱ្យមានទំនាក់ទំនងស្នេហាជាតិ។ | ៣ម៉ |
| **មេរៀនទី៥** : **ឆន្ទៈ**<br>៥.១- និយមន័យ<br>៥.២- វិភាគអំពើឆន្ទៈ<br>៥.៣- ធម្មជាតិនៃឆន្ទៈ<br>៥.៤- ប្រភពនៃឆន្ទៈ<br>៥.៥- សារៈសំខាន់នៃការមានឆន្ទៈ<br>៥.៦- ការបណ្តុះឆន្ទៈ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យឆន្ទៈ និងអំពើអឆន្ទៈ។<br>**បំណិនសម្បទា**<br>- វិភាគអំពើនៃឆន្ទៈ ធម្មជាតិនៃឆន្ទៈ ប្រភពនៃឆន្ទៈ និងការបណ្តុះឆន្ទៈ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីធ្វើអំពើប្រកបដោយឆន្ទៈ។ | ៣ម៉ |
| **មេរៀនទី៦** : **តម្លៃនៃកាតព្វកិច្ច ករណីយកិច្ច និងកុសល**<br>៦.១- និយមន័យ<br>៦.២- កាតព្វកិច្ច ករណីយកិច្ចឪពុកម្តាយ និងកូន<br>៦.៣- កាតព្វកិច្ច ករណីយកិច្ចពលរដ្ឋ និងសង្គម<br>៦.៤- សីលកុសល និងការបណ្តុះសីលកុសល<br>៦.៥- ប្រៀបធៀបកាតព្វកិច្ច ករណីយកិច្ច និងកុសល | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ករណីយកិច្ច និងសីលកាតព្វកិច្ច<br>- បង្ហាញកាតព្វកិច្ច ករណីយកិច្ចឪពុកម្តាយ និងកូន ពលរដ្ឋ និងសង្គម។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់ករណីកិច្ច និងកាតព្វកិច្ចប្រកបដោយកុសលសម្រាប់គ្រួសារ និងសង្គម<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់នូវតម្លៃ ករណីកិច្ច កាតព្វកិច្ច និងអំពើជាកុសល។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៧ : សីលញាណ និងចិត្តញាណ**<br>៧.១- និយមន័យ<br>៧.២- ធម្មជាតិនៃសីលញាណ និងចិត្តញាណ<br>៧.៣- ដើមកំណើតនៃសីលញាណ និងចិត្តញាណ<br>○ ទ្រឹស្តីចេញពីកំណើត<br>○ ទ្រឹស្តីពិសោធនិយម<br>○ ទ្រឹស្តីវិចារណញ្ញាណនិយម<br>៧.៤- បម្រែបម្រួលសីលញាណ និងចិត្តញាណ<br>៧.៥- ការទទួលខុសត្រូវចំពោះសង្គម និងសីលធម៌ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ចិត្តញាណ និងសីលញាណ<br>- រៀបរាប់អំពីធម្មជាតិ និងដើមកំណើតនៃសីលញាណ និងចិត្តញាណ។<br>**បំណិនសម្បទា**<br>- បង្ហាញអំពីបម្រែបម្រួលសីលញាណ និងចិត្តញាណ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ការដោះស្រាយបញ្ហាផ្សេងៗដោយកុសល។ | ៤ម៉ |
| **មេរៀនទី៨ : តម្លៃ និងសីលវិជ្ជា**<br>**៨.១- តម្លៃ**<br>៨.១.១- និយមន័យ<br>៨.១.២- ទីតាំងនៃតម្លៃ<br>៨.១.៣- ប្រភេទនៃតម្លៃ<br>៨.១.៤- ចំណាត់ថ្នាក់នៃតម្លៃ<br>៨.១.៥- ធម្មជាតិនៃសីលតម្លៃ<br>៨.១.៦- តម្លៃ និងសារៈសំខាន់<br>**៨.២- សីលវិជ្ជា**<br>៨.២.១- និយមន័យ<br>៨.២.២- បញ្ញត្តិសីលវិជ្ជា<br>៨.២.៣- តម្លៃនៃការសិក្សាសីលវិជ្ជា<br>៨.២.៤- សីលធម៌ជាភាពថ្លៃថ្នូរបំផុតសម្រាប់មនុស្ស<br>៨.២.៥- សេរីភាពជាមូលដ្ឋាននៃសីលធម៌<br>៨.២.៦- ហេតុផលបណ្តាលឱ្យមានសីលធម៌<br>៨.២.៧- ការវិនិច្ឆ័យសំខាន់ៗនៃធម្មចរិយា<br>៨.២.៨- គុណតម្លៃ និងការគោរពអ្នកដទៃនៅក្រៅក្រុមរបស់ខ្លួន | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ តម្លៃ និងសីលវិជ្ជា<br>- កំណត់ទីតាំងនៃតម្លៃ ប្រភេទនៃតម្លៃ និងធ្វើចំណាត់ថ្នាក់នៃតម្លៃ។<br>**បំណិនសម្បទា**<br>- វែកញែកពីតម្លៃ និងសីលវិជ្ជា និងអាចធ្វើចំណាត់ថ្នាក់តម្លៃ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់សីលធម៌ក្នុងការរស់នៅ សីលធម៌ផ្នែកហិរញ្ញវត្ថុ គោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស គុណតម្លៃ និងគោរពអ្នកដទៃ។ | ៤ម៉ |
| **មេរៀនទី៩ : ទំនួលខុសត្រូវ និងវិបាកវិនិច្ឆ័យ**<br>៩.១- និយមន័យ<br>៩.២- ប្រភេទនៃទំនួលខុសត្រូវ<br>៩.៣- ទំនាក់ទំនងទំនួលខុសត្រូវផ្នែកសីលវិជ្ជា | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ និងពណ៌នាពីលក្ខណៈនៃទំនួលខុសត្រូវ និងវិបាកវិនិច្ឆ័យ។<br>**បំណិនសម្បទា**<br>- បង្ហាញពីទំនាក់ទំនងរវាងទំនួលខុសត្រូវ | ៤ម៉ |

| | | |
|---|---|---|
| និងផ្នែកសង្គម<br>៩.៤- ទ្រឹស្តីផ្សេងៗនៃទំនួលខុសត្រូវ<br>៩.៥- វិបាកវិនិច្ឆ័យ<br>៩.៦- បញ្ញត្តិកម្មនៃវិបាកវិនិច្ឆ័យ<br>៩.៧- ទ្រឹស្តីផ្សេងៗនៃវិបាកវិនិច្ឆ័យ<br>៩.៨- ទំនាក់ទំនងរវាងទំនួលខុសត្រូវ និងវិបាកវិនិច្ឆ័យ | ផ្នែកសីលវិជ្ជា និងផ្នែកសង្គម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីទទួលខុសត្រូវចំពោះទង្វើ និងសកម្មភាពរបស់ខ្លួន ក្នុងនាមជាសមាជិកសហគមន៍ និងសកលលោក។ | |
| **មេរៀនទី១០ : គោលការណ៍ទូទៅនៃច្បាប់**<br>១០.១- និយមន័យ<br>១០.២- មូលហេតុនៃការបង្កើតច្បាប់<br>១០.៣- ប្រភព ប្រភេទ និងលក្ខណៈនៃច្បាប់<br>១០.៤- ឋានានុក្រមនៃច្បាប់<br>១០.៥- មុខងារច្បាប់នៅក្នុងសង្គម | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ ច្បាប់<br>- រៀបរាប់អំពីសញ្ញាណ លក្ខណៈផ្សេងៗ និងមូលហេតុនៃការបង្កើតច្បាប់ ដើម្បីបង្ការបទល្មើស និងរៀបចំរបៀបរៀបរយសង្គម។<br>**បំណិនសម្បទា**<br>- បកស្រាយគោលការណ៍ទូទៅ នៃច្បាប់ តាមធម្មជាតិ តាមន័យច្បាប់ និងតាមទ្រឹស្តីទស្សនវិជ្ជា។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រឡាញ់ និងអនុវត្តច្បាប់បានត្រឹមត្រូវ។ | ៣ម៉ |
| **ជំពូកទី២ : ទំនាក់ទំនងល្អក្នុងសហគមន៍** | | |
| **មេរៀនទី១ : កម្រិតផ្សេងៗនៃអត្តសញ្ញាណ**<br>២.១- អត្តសញ្ញាណបុគ្គល និងសមាជិកភាពក្នុងបរិបទជាតិ តំបន់ និងសកល<br>២.២- អត្តសញ្ញាណរួម តម្លៃរួម និងផលប៉ះពាល់ដល់ការបង្កើតវប្បធម៌ពលរដ្ឋជាសកលមួយ<br>២.៣- គោលគំនិត និងសញ្ញាណប្រកបដោយភាពស្មុគស្មាញ និងពិពិធភាពនៃអត្តសញ្ញាណពលរដ្ឋសកល | **វិជ្ជាសម្បទា**<br>- កំណត់បានពីអត្ថន័យនៃអត្តសញ្ញាណ និងសមាជិកភាព តាមកម្រិតនៃបរិបទផ្សេងៗ (បុគ្គល ជាតិ និងសកល)។<br>**បំណិនសម្បទា**<br>- បង្ហាញទំនាក់ទំនងនៃអត្តសញ្ញាណរវាងទស្សនវិជ្ជា និងវិទ្យាសាស្ត្រ និង ទស្សនវិជ្ជា និងសង្គម។<br>**ចរិយាសម្បទា**<br>- គោរព និងឱ្យតម្លៃលើអត្តសញ្ញាណខុសៗគ្នា និងចេះរួមរស់ក្នុងសង្គមដែលមានវប្បធម៌ចម្រុះជាមួយគ្នា។ | |
| **មេរៀនទី២ : ទម្រង់នៃការគ្រប់គ្រងរដ្ឋ**<br>២.១- ទ្រឹស្តីរដ្ឋ<br>២.២- ការបង្កើតរដ្ឋ | **វិជ្ជាសម្បទា៖**<br>- កំណត់បានពីទ្រឹស្តី ការបង្កើតរដ្ឋ អំណាចរដ្ឋ និងទម្រង់រដ្ឋ។ | ៣ម៉ |

| | | |
|---|---|---|
| ២.៣- អំណាចរដ្ឋ<br>២.៤- ទម្រង់រដ្ឋ<br>២.៥- ការទទួលស្គាល់រដ្ឋ<br>២.៦- ធាតុផ្សំរបស់រដ្ឋ | **បំណិនសម្បទាៈ**<br>- បង្ហាញទ្រឹស្តី ការបង្កើត អំណាចរដ្ឋ និង ទម្រង់រដ្ឋ ធាតុផ្សំរបស់រដ្ឋ និងការទទួល ស្គាល់រដ្ឋ។<br>**ចរិយាសម្បទាៈ**<br>- មានស្មារតីគោរពរដ្ឋ ការប្រើអំណាចរដ្ឋ ឱ្យបានត្រឹមត្រូវ ។ | |
| **មេរៀនទី៣** : **មាតាធិបតេយ្យ និងសិទ្ធិស្ត្រី**<br>៣.១- និយមន័យ<br>៣.២- ប្រវត្តិមាតាធិបតេយ្យនៅក្នុងសង្គមខ្មែរ<br>៣.៣- តួនាទីស្ត្រីនៅក្នុងសង្គម<br>៣.៤- ស្ត្រី និងការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ<br>៣.៥- សមភាពរវាងស្ត្រី និងបុរសក្នុងវិស័យការងារ | **វិជ្ជាសម្បទា**<br>- រៀបរាប់បានពីតួនាទីស្ត្រីក្នុងសង្គម។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីសមភាពរវាងស្ត្រី និងបុរស ក្នុងវិស័យការងារ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរព និងឱ្យតម្លៃស្ត្រី។ | ៣ម៉ |
| **មេរៀនទី៤** : **អភិបាលកិច្ច**<br>៤.១- និយមន័យ<br>៤.២- ធាតុសំខាន់ៗនៃអភិបាលកិច្ច<br>៤.៣- សារៈសំខាន់នៃអភិបាលកិច្ច<br>៤.៤- ការដឹកនាំ និងគ្រប់គ្រងសហគមន៍តាម គោលការណ៍អភិបាលកិច្ចល្អ | **វិជ្ជាសម្បទា**<br>- ពណ៌នាពីអត្ថន័យនៃអភិបាលកិច្ច ធាតុសំខាន់ៗនៃគោលការណ៍អភិបាល កិច្ចនៅកម្ពុជារួមមានការចូលរួម តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាព ស័ក្តិសិទ្ធ ច្បាប់ ការព្រមព្រៀង។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់អភិបាលកិច្ចក្នុងការសម្រេចចិត្ត និងការគ្រប់គ្រងសហគមន៍។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីចូលរួមអភិបាលកិច្ច។ | ៣ម៉ |
| **មេរៀនទី៥** : **នីតិរដ្ឋ**<br>៥.១- និយមន័យ<br>៥.២- គោលការណ៍សំខាន់ៗរបស់នីតិរដ្ឋ<br>៥.៣- អត្ថប្រយោជន៍នៃការអនុវត្តច្បាប់<br>៥.៤- ការចូលរួមគោរពច្បាប់ នៅសាលារៀន សហគមន៍ និងសង្គម | **វិជ្ជាសម្បទា**<br>- កំណត់ពីអត្ថន័យ គោលការណ៍ និង អត្ថប្រយោជន៍នីតិរដ្ឋ។<br>**បំណិនសម្បទា**<br>- អនុវត្តច្បាប់នៅតាមសាលារៀន សហគមន៍ និងសង្គម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរព ស្រឡាញ់នីតិរដ្ឋ។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៦: ភាពជាអ្នកដឹកនាំក្នុងសហគមន៍**<br>៦.១- និយមន័យ<br>៦.២- ប្រភេទនៃអ្នកដឹកនាំ<br>៦.៣- ភាពខុសគ្នារវាងអ្នកដឹកនាំ និងអ្នកគ្រប់គ្រង<br>៦.៤- ទ្រឹស្តីផ្សេងៗភាពជាអ្នកដឹកនាំ<br>៦.៥- លក្ខណសម្បត្តិមេដឹកនាំល្អ និងមិនល្អ<br>៦.៦- វិធីដើម្បីក្លាយជាអ្នកដឹកនាំល្អ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីភាពជាអ្នកដឹកនាំ តួនាទី និងភារកិច្ច។<br>**បំណិនសម្បទា**<br>- បង្ហាញបានលក្ខណវិនិច្ឆ័យក្នុងភាពជាអ្នកដឹកនាំល្អ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីដឹកនាំ ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។ | ៣ម៉ |
| **មេរៀនទី៧ : ស្ថាប័ននយោបាយនៅកម្ពុជា**<br>៧.១- និយមន័យស្ថាប័ន<br>៧.២- ប្រភេទស្ថាប័ន<br>៧.៣- ស្ថាប័នរដ្ឋធម្មនុញ<br>៧.៤- ស្ថាប័ននីតិប្បញ្ញត្តិ<br>៧.៥- ស្ថាប័នប្រតិបត្តិ<br>៧.៦- ស្ថាប័នតុលាការ<br>៧.៧- ទំនាក់ទំនងរវាងស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្ត និងតុលាការ | **វិជ្ជាសម្បទា**<br>- រៀបរាប់ខ្លឹមសារ រដ្ឋម្មនុញ និងតួនាទីស្ថាប័ន កំពូល ដូចជានីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីតួនាទីស្ថាប័នរដ្ឋធម្មនុញ នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរពប្រតិបត្តិ រដ្ឋធម្មនុញ និងកែលម្អស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ | ៣ម៉ |
| **មេរៀនទី៨ : រដ្ឋបាលមូលដ្ឋាន**<br>៨.១- និយមន័យ<br>៨.២- រចនាសម្ព័ន្ធនៃរដ្ឋបាលមូលដ្ឋាន<br>៨.៣- វិមជ្ឈការ និងវិសហមជ្ឈការរដ្ឋបាលមូលដ្ឋាន<br>៨.៤- បទដ្ឋានសំខាន់ៗពាក់ព័ន្ធរដ្ឋបាលមូលដ្ឋាន<br>៨.៥- អាជ្ញាធររដ្ឋបាលឯករាជ្យ ឬមិនឯកភាព | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ មជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ<br>- រៀបរាប់រចនាសម្ព័ន្ធនៃរដ្ឋបាលមូលដ្ឋាន។<br>**បំណិនសម្បទា**<br>- បង្ហាញភាពខុសគ្នានៃមជ្ឈការ វិមជ្ឈការ និងវិសហមជ្ឈការ<br>- បង្ហាញតួនាទីរបស់អាជ្ញាធររដ្ឋបាលមូលដ្ឋាន។<br>**ចរិយាសម្បទា**<br>- ចូលរួមសកម្មភាពអភិវឌ្ឍនៅមូលដ្ឋាន។ | ៣ម៉ |

| | | |
|---|---|---|
| **មេរៀនទី៩ : ដំណោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ**<br>៩.១- និយមន័យ<br>៩.២- មូលហេតុជម្លោះ និងដំណោះស្រាយ<br>៩.៣- ការផ្សះផ្សារ ជម្លោះភាគីទំនាស់<br>៩.៤- ដំណោះស្រាយកម្រិតតុលាការជាតិ និង អន្តរជាតិ<br>៩.៥- ការសម្រុះសម្រួល មជ្ឈិត្តកម្ម ការដាក់ទណ្ឌកម្ម សម្ព័ន្ធភាព<br>៩.៦- សារៈសំខាន់នៃការដោះស្រាយក្រៅប្រព័ន្ធតុលាការ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីមូលហេតុនៃជម្លោះនិងវិធីផ្សេងៗសម្រាប់ដោះស្រាយជម្លោះ រួមទាំងជម្លោះផ្នែកហិរញ្ញវត្ថុ។<br>**បំណិនសម្បទា**<br>- ស្វែងយល់អនុវត្តវិធីដោះស្រាយទំនាស់ដោយការផ្សះផ្សារ និងមជ្ឈត្តការ។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់ធម៌អហិង្សាក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី។ | ៣ម៉ |
| **មេរៀនទី១០ : ការបង្ការបទល្មើស**<br>១០.១- និយមន័យ<br>១០.២- មូលហេតុដែលនាំឱ្យកើតមានបទល្មើស<br>១០.៣- ប្រភេទនៃបទល្មើស<br>១០.៤- សមត្ថកិច្ចក្នុងការបង្ក្រាបបទល្មើស<br>១០.៥- តួនាទីពលរដ្ឋក្នុងការបង្ការបទល្មើស<br>១០.៦- ផលប៉ះពាល់នៃបទល្មើស<br>១០.៧- វិធានការបង្ការ និងលុបបំបាត់បទល្មើស | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យ បទល្មើស<br>- រៀបរាប់ពីប្រភេទ មូលហេតុដែលនាំឱ្យកើតមានបទល្មើស និងវិធានការទប់ស្កាត់ក្នុងសង្គម។<br>**បំណិនសម្បទា**<br>- បង្ហាញពីផលប៉ះពាល់ ដំណោះស្រាយ និងតួនាទីសមត្ថកិច្ចនៃបទល្មើសក្នុងសង្គម។<br>**ចរិយាសម្បទា**<br>- បណ្ដុះស្មារតីទប់ស្កាត់ បង្ការ និងលុបបំបាត់បទល្មើសក្នុងសង្គម។ | ៣ម៉ |
| **ជំពូកទី៣ : វប្បធម៌ សាសនា និងការអប់រំ** | | |
| **មេរៀនទី១ : ការគោរពពិពិធភាព**<br>៣.១- និយមន័យ<br>៣.២- ការគោរពភាពផ្សេងៗគ្នា<br>៣.៣- រចនាសម្ព័ន្ធសង្គម<br>៣.៤- ធាតុផ្សេងគ្នារបស់ពិពិធភាព | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យពិពិធភាព<br>- ប្រាប់បានពីភាពផ្សេងគ្នានៃ វប្បធម៌ (ភេទ ជនជាតិភាគតិច វណ្ណៈ ឋានៈសង្គម សាសនា ប្រពៃណី តម្លៃ ជំនឿ)។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីតម្លៃនៃពិពិធភាពវប្បធម៌ សាសនា និងរចនាសម្ព័ន្ធសង្គម<br>- បង្ហាញបានពី (១)ជាតិសាសន៍ ជនជាតិភាគតិច ភេទ អាយុ..(២) សាសនា វប្បធម៌ (៣) ជំនឿ ឥរិយាបថ អារម្មណ៍។ | ៣ម៉ |

| | | |
|---|---|---|
| | **ចរិយាសម្បទា**<br>- មានស្មារតីស្រឡាញ់ និងគោរពពី ពិពិធភាពរបស់មនុស្ស និងសង្គមមនុស្ស។ | |
| **មេរៀនទី២ : ព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស**<br>២.១- ទ្រឹស្តីពុទ្ធសាសនា និងសិទ្ធិមនុស្ស<br>២.១- ទំនាក់ទំនងព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស<br>២.១- ការប្រតិបត្តិសិទ្ធិមនុស្សក្នុងសង្គមខ្មែរ | **វិជ្ជាសម្បទា**<br>- ពណ៌នាពីទ្រឹស្តីពុទ្ធសាសនា និងសិទ្ធិមនុស្ស។<br>**បំណិនសម្បទា**<br>- បង្ហាញទំនាក់ទំនងសិទ្ធិមនុស្ស និងទ្រឹស្តីអប់រំព្រះពុទ្ធសាសនា។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរពប្រតិបត្តិទ្រឹស្តីព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស។ | ៣ម៉ |
| **មេរៀនទី៣ : ការប្រតិបត្តិសាសនាក្នុងសង្គមខ្មែរ**<br>៣.១- ឥទ្ធិពលពុទ្ធសាសនា និងព្រហ្មញ្ញសាសនាលើសង្គមខ្មែរ<br>៣.២- ផលវិជ្ជមាន និងអវិជ្ជមាននៃការប្រតិបត្តិពុទ្ធសាសនា និងព្រាហ្មសាសនាក្នុងជីវភាពរស់នៅ<br>៣.៣- ការប្រារព្ធពិធីសាសនាផ្សេងៗក្នុងសង្គមខ្មែរ | **វិជ្ជាសម្បទា**<br>- ពណ៌នាឥទ្ធិពលពុទ្ធសាសនា និងព្រាហ្មសាសនាមកលើសង្គមខ្មែរនិងផលប៉ះពាល់។<br>**បំណិនសម្បទា**<br>- ប្រើប្រាស់ឥទ្ធិពលពុទ្ធសាសនា និងព្រាហ្មសាសនាជាគុណតម្លៃ។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរពប្រតិបត្តិ និងមានទំនួលខុសត្រូវ។ | ៣ម៉ |
| **មេរៀនទី៤ : សុខដុមនីយកម្មសាសនា**<br>៤.១- និយមន័យ<br>៤.២- សារៈសំខាន់នៃការអត់ឱនក្នុងជំនឿសាសនា<br>៤.៣- ភាពផ្សេងគ្នានៃការគោរពសាសនា<br>៤.៤- សាសនាជនជាតិភាគតិច | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីសមាសភាគនៃសុខដុមនីយកម្មក្នុងសាសនាទាំងបី ព្រះពុទ្ធ ឥស្លាម គ្រិស្ត។<br>**បំណិនសម្បទា**<br>- បង្ហាញពីអត្ថប្រយោជន៍ក្នុងប្រតិបត្តិសាសនា។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរពស្រឡាញ់ និងឱ្យតម្លៃ។ | ៣ម៉ |
| **មេរៀនទី៥ : សីលធម៌សកល**<br>៥.១- និយមន័យ<br>៥.២- ប្រវត្តិកំណើតសីលធម៌សកល<br>៥.៣- ខ្លឹមសារសីលធម៌សកល<br>៥.៤- មូលហេតុនានានាំឱ្យមានវិបត្តិសង្គម | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យសីលធម៌សកល<br>- រៀបរាប់ប្រវត្តិកំណើតសីលធម៌សកល អហិង្សា គោរពជីវិត យុត្តិធម៌ សាមគ្គីធម៌ សច្ចធម៌ ធម៌អធ្យាស្រ័យ ភាពជាដៃគូ | ២ម៉ |

| | | |
|---|---|---|
| ៥.៥- សីលធម៌សកល និងសកលភាវូបនីយកម្ម | និងការគោរពរាប់អានគ្នាទៅវិញទៅមក និងខ្លឹមសារៈសំខាន់ៗរបស់វា។<br>**បំណិនសម្បទា**<br>- បង្ហាញពីមូលហេតុដែលនាំឱ្យកើតមានវិបត្តិសង្គម និងភាពចាំបាច់នៃការប្រើប្រាស់សីលធម៌សកលជាមួយសកលភាវូបនីយកម្ម។<br>**ចរិយាសម្បទា**<br>- ប្រកាន់ខ្ជាប់តវិយាបថវិជ្ជមាន។ | |
| **មេរៀនទី៦ : មោទនភាពជាតិខ្មែរ**<br>៦.១- និយមន័យ<br>៦.២- អត្តសញ្ញាណជាតិ<br>៦.៣- វប្បធម៌ និងអរិយធម៌<br>៦.៤- ភូមិសាស្ត្រ<br>៦.៥- អ្នកដឹកនាំគម្រូ<br>៦.៦- លក្ខណៈជាតិនិយម | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យមោទនភាពជាតិខ្មែរ<br>- រៀបរាប់បានពី អត្តសញ្ញាណជាតិ វប្បធម៌ អរិយធម៌ ភូមិសាស្ត្រ មេដឹកនាំគម្រូ និង លក្ខណៈជាតិនិយមរបស់ខ្មែរ។<br>**បំណិនសម្បទា**<br>- បង្ហាញបានពីធាតុសំខាន់ៗនាំឱ្យខ្មែរមានមោទនភាពជាតិ<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រឡាញ់ អត្តសញ្ញាណជាតិ វប្បធម៌ អរិយធម៌ ភូមិសាស្ត្រ និង ជាតិខ្មែរ។ | ៣ម៉ |
| **ជំពូកទី៤ : សង្គមយើង** | | |
| **មេរៀនទី១ : ការរៀបចំ និងធ្វើផែនការសម្រាប់អនាគត**<br>១.១- និយមន័យ<br>១.២- ធាតុផ្សំនៃផែនការ<br>១.៣- ការកំណត់ និងវិភាគបញ្ហាផែនការ<br>១.៤- កំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្រ<br>១.៥- របៀបរៀបចំ និងធ្វើផែនការសកម្មភាព | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យផែនការ<br>- រៀបរាប់ពីដំណើការ សកម្មភាព ពេលវេលា ថវិកា ការធ្វើផែនការ។<br>**បំណិនសម្បទា**<br>- បង្ហាញពីរបៀបនៃការរៀបចំ និងធ្វើផែនការ។<br>**ចរិយាសម្បទា**<br>- មានស្មារតីយកចិត្តទុកដាក់ធ្វើផែនការ និងអនុវត្តផែនការ។ | ៣ម៉ |
| **មេរៀនទី២ : ការធ្វើចំណាកស្រុកដោយសុវត្ថិភាព**<br>២.១- និយមន័យ<br>២.២- មូលហេតុនៃការធ្វើចំណាកស្រុក | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យចំណាកស្រុក ជនអន្តោប្រវេសន៍ ទេសន្តប្រវេសន៍<br>- ប្រាប់បានពីមូលហេតុនៃការចំណាក | ៣ម៉ |

| | | |
|---|---|---|
| ២.៣- គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើចំណាកស្រុក<br>២.៤- មធ្យោបាយក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព<br>២.៥- វិធិសាស្ត្រជួយជនរងគ្រោះ និងទប់ស្កាត់ការធ្វើចំណាកស្រុក<br>២.៦- ល្បិចកលជនខិលខូចក្នុងការអូសទាញឱ្យធ្វើចំណាកស្រុក<br>២.៧- បញ្ហាជនភៀសខ្លួន ទេសន្តប្រវេសន៍ និងភាពគ្មានការងារធ្វើរបស់យុវជន | ស្រុក។<br>**បំណិនសម្បទា**<br>- បង្ហាញពីគុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើចំណាកស្រុក និងវិធីសាស្ត្រក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាព<br>- ប្រាប់ពីល្បិចកលជនខិលខូចក្នុងការអូសទាញឱ្យធ្វើចំណាកស្រុក។<br>**ចរិយាសម្បទា**<br>- មានស្មារតីប្រុងប្រយត្នពេលធ្វើចំណាកស្រុក។ | |
| **មេរៀនទី៣** : **អំពើពុករលួយ និងការបង្ការបទល្មើស**<br>៣.១- និយមន័យ<br>៣.២- មូលហេតុនៃអំពើពុករលួយ<br>៣.៣- ប្រភេទនៃអំពើពុករលួយ<br>៣.៤- ផលវិបាកនៃអំពើពុករលួយ<br>៣.៥- ការបង្ការ និងដោះស្រាយបញ្ហាអំពើពុករលួយ | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យអំពើពុករលួយ<br>- ប្រាប់ពីតួអង្គ គោលបំណង សកម្មភាព និងផលប៉ះពាល់នៃអំពើពុករលួយ។<br>**បំណិនសម្បទា**<br>- វិភាគសកម្មភាពមួយចំនួនដែលជាអំពើពុករលួយក្នុងសង្គម។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្អប់ខ្ពើមអំពើពុករលួយ។ | ៣ម៉ |
| **មេរៀនទី៤** : **គណនេយ្យភាពសង្គម**<br>៤.១- និយមន័យ<br>៤.២- ធាតុសំខាន់ៗនៃគណនេយ្យភាពសង្គម<br>៤.៣- ភាពចាំបាច់ត្រូវមានគណនេយ្យភាពសង្គម<br>៤.៤- ការចូលរួមដើម្បីឱ្យមានគណនេយ្យភាពសង្គម | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យគណនេយ្យភាព និងគណនេយ្យភាពសង្គម។<br>**បំណិនសម្បទា**<br>- វិភាគលើកត្តាទាំងឡាយដើម្បីឱ្យសង្គមមានគណនេយ្យភាព។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីអភិវឌ្ឍ និងទំនួលខុសត្រូវក្នុងសហគមន៍។ | ៣ម៉ |
| **មេរៀនទី៥** : **សីលធម៌ និងសហគ្រិនភាព**<br>៥.១- និយមន័យ<br>៥.២- ភាពចាំបាច់នៃសហគ្រិនភាពសង្គម<br>៥.៣- ការស្វែងរកឱកាសសម្រាប់អនុវត្តសហគ្រិនភាពសង្គម<br>៥.៤- យុវជន និងសហគ្រិនភាព | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យសហគ្រិនភាពសង្គម។<br>**បំណិនសម្បទា**<br>- វិភាគកត្តាចាំបាច់ដើម្បីបង្កើតសហគ្រិនភាពសង្គម។<br>**ចរិយាសម្បទា**<br>- មានស្មារតីបង្កើតសហគ្រិនភាពសង្គម។ | ២ម៉ |

| | | |
|---|---|---|
| **មេរៀនទី៦ : អាស៊ាន និងសុខដុមនីយកម្ម**<br>៦.១- និយមន័យ<br>៦.២- ទស្សនទាននៃសមាគមអាស៊ាន<br>៦.៣- សហគមន៍តែមួយ វាសនាតែមួយ<br>៦.៤- ទំនាក់ទំនងកម្ពុជាជាមួយបណ្តាប្រទេសអាស៊ាន | **វិជ្ជាសម្បទា**<br>- កំណត់និយមន័យអាស៊ាន និងសុខដុមនីយកម្ម<br>- បង្ហាញពីទស្សនទានសហគមន៍អាស៊ាន និងសំខាន់នៃការចូលជាសមាគន៍អាស៊ាន។<br>**បំណិនសម្បទា**<br>- បង្ហាញទំនាក់ទំនងកម្ពុជា និងអាស៊ានលើវិស័យការទូត នយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ និងសង្គមកិច្ច។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីស្រឡាញ់ លើកស្ទួយ និងចូលរួមសហការក្នុងនាមជាប្រជាជាតិអាស៊ាន។ | ២ម៉ |
| **មេរៀនទី៧ : គោលការណ៍សញ្ជាតិ និងអន្តោប្រវេសន៍**<br>៧.១- ច្បាប់សញ្ជាតិ និងការចូលសញ្ជាតិ<br>៧.២- លក្ខណៈទូទៅនៃច្បាប់អន្តោប្រវេសន៍<br>៧.៣- ការទទួលបានសញ្ជាតិខ្មែរ និងការបាត់បង់សញ្ជាតិ<br>៧.៤- ប្រភេទជនបរទេស<br>៧.៥- ការគ្រប់គ្រងជនបរទេសនៅកម្ពុជា | **វិជ្ជាសម្បទា**<br>- ពណ៌នាពីលក្ខណៈទូទៅនៃច្បាប់អន្តោប្រវេសន៍ និង ប្រភេទជនបរទេសដូចជាជនបរទេសអន្តោប្រវេសន៍ ជនបរទេសមិនមែនអន្តោប្រវេសន៍ និងជនបរទេសអន្តោប្រវេសន៍វិនិយោគឯកជន។<br>**បំណិនសម្បទា**<br>- បង្ហាញពីប្រភេទ និងការគ្រប់គ្រងជនបរទេសនៅកម្ពុជា។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីគោរពច្បាប់អន្តោប្រវេសន៍ និងមានទំនាក់ទំនងល្អជាមួយជនជាតិផ្សេងៗ។ | ២ម៉ |
| **មេរៀនទី៨ : សិទ្ធិស្ត្រី និងសិទ្ធិមនុស្ស**<br>៨.១- ខ្លឹមសារសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស និងសិទ្ធិស្ត្រី<br>៨.២- ទស្សនវិស័យបែបសាសនា និងវប្បធម៌ចំពោះសិទ្ធិស្ត្រី<br>៨.៣- ខ្លឹមសារ និងអត្ថន័យនៃមាត្រាទាំង៣០ក្នុងអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ | **វិជ្ជាសម្បទា**<br>- រៀបរាប់សេចក្តីថ្លែងការណ៍ជាសកលអំពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងទស្សនវិស័យសាសនាចំពោះសិទ្ធិស្ត្រី<br>- ពណ៌នាអត្ថន័យនៃអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។ | ៣ម៉ |

| | | |
|---|---|---|
| ៨.៤- វិធីលើកស្ទួយសិទ្ធិស្ត្រី | **បំណិនសម្បទា**<br>- វិភាគទស្សនវិស័យសាសនាទាក់ទង និងសិទ្ធិស្ត្រី<br>- បង្ហាញអំពីវិធីនៃការលើកស្ទួយសិទ្ធិស្ត្រី។<br>**ចរិយាសម្បទា**<br>- បណ្តុះស្មារតីលើកកម្ពស់តម្លៃ តួនាទីស្ត្រីនៅក្នុងសង្គម។ | |
| **មេរៀនទី៩** : **សង្គម និងយុត្តិធម៌**<br>៩.១- និយមន័យ<br>៩.២- កំណកំណើតសង្គម<br>៩.៣- ការកកើតច្បាប់ និងការអនុវត្តច្បាប់<br>៩.៤- ធាតុចាំបាច់ចំពោះយុត្តិធម៌សង្គម<br>៩.៥- ពលរដ្ឋ និងការគោរពច្បាប់ | **វិជ្ជាសម្បទា**<br>- កំណត់ពីអត្ថន័យ សង្គម យុត្តិធម៌ ច្បាប់ ការកកើតសង្គមតាមទស្សនវិទូ។<br>**បំណិនសម្បទា**<br>- បង្ហាញពីធាតុចាំបាច់ដើម្បីឱ្យមានយុត្តិធម៌សង្គម។<br>**ចរិយាសម្បទា**<br>- ចូលរួមការពារយុត្តិធម៌ និងគោរពច្បាប់ដើម្បីសេចក្តីសុខសង្គម។ | ៣ម៉ |

## ៨- ឯកសារយោង

### ក. ភាសាខ្មែរ


១- ក្រសួងអប់រំ យុវជន និងកីឡា, កម្មវិធីសិក្សាសង្គមថ្នាក់ទី១០ ទី១១ និងទី១២ ដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន, គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឆ្នាំ២០១៦ ។
២- ឯកសាររបស់ធនាគាជាតិ (បញ្ញាបការអប់រំហិរញ្ញវត្ថុ)
៣- APCEIU, ការអប់រំពលរដ្ឋសកល (Global citizenship Education) របស់ APCEIU និងUNES CO
៤- ឡុច ចាន់ថន, របាយការណ៍ស្រាវជ្រាវ "គុណភាពនៃការរៀន និងការបង្រៀន សីលធម៌ពលរដ្ឋវិជ្ជានៅកម្ពុជា" ឆ្នាំសិក្សា ២០១៤ -២០១៥ ។
៥- សម្តេច ជួន ណាត វចនានុក្រមខ្មែរ ភាគ១ ភាគ២ បោះពុម្ពលើកទី៥ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ ភ្នំពេញ ឆ្នាំ១៩៦៧
៦- សុខ គាង វិទ្យាសាស្ត្រនយោបាយ ភ្នំពេញ ឆ្នាំ២០០២
៧- ឃុន ណារ៉េត ប្រវត្តិគំនិតនយោបាយ និងវិទ្យាសាស្រ្តនយោបាយ ភ្នំពេញ
៨- ក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពប្រឆាំងអំពើពុករលួយ ការអប់រំស្តីពី ការប្រឆាំងអំពើពុករលួយសម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ភ្នំពេញ ឆ្នាំ២០១៤
៩- ត្រឹង ងា អរិយធម៌ខ្មែរសម្រាប់ថ្នាក់បញ្ចប់ ឆ្នាំ១៩៧៤
១០- អ៊ុន លាង ទស្សនវិជ្ជាអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំ២០០៥
១១- ក្រុមអ្នកនិពន្ធ "ទស្សនវិជ្ជាថ្នាក់បញ្ចប់ " បោះពុម្ពដោយ វិទ្យាស្ថានជាតិខេមរយានកម្ម ភាគ១-២, ១៩៧៤
១២- ឈត ប៊ុនថន "ទស្សនវិជ្ជាសីលធម៌" ភ្នំពេញ , ២០០៥
១៣- ឈត ប៊ុនថន "សីលធម៌អនុវត្ត" ភ្នំពេញ , ២០០២
១៤- ម៉យ ស៊ីណន "ទស្សនវិជ្ជាមនុស្ស" បោះពុម្ពលើកទី៣, ភ្នំពេញ , ២០១៧
១៥- ក្រុមសាស្ត្រាចារ្យទស្សនវិជ្ជា "គ្រឹះរបស់ទស្សនវិជ្ជា" ភ្នំពេញ , ២០០៦
១៦- ទស្សនាវដ្តីសុខភាពលេខ១៥ "សុខភាពផ្លូវចិត្ត" ភ្នំពេញ , ២០០៣


### ខ.ភាសាបរទេស


១. Beatrice Neall, Compiller, and Sophat Sorn (Translator) ស្ពានកម្ពុជាឱ្យប្រសើរ Seventh-day Adventist Mission ឆ្នាំ២០១៣
២. Aruego.Jose M.and Gloria E. Aruego-Torres. Principle of Political Science, Manila: University Book Supply. Inc 1981.
៣.Myra Pollack Sadker and Devid Miller Sadker. Teachers, Schools, and Societies. McGraw-Hill Higher Education. Sixth edition 2003
៤. Chava Frankfort-Nachmias and Devid Nachmias. Research Methods in The Social Sciences. Fifth Edition. 1996
៥. Palgrave Macmillain, and Johana Mair, Jeffrey Robinson, Kai Hockerts(Editors). Social Entrepreneurship. Antony Rowe Ltd, Chippenham and Eastbourne. 2006
៦. James L. Christian "Philosophy: An Introduction to the Art of Wondering " Tenth Edition, Canada, 2009
៧. Brooke Noel Moore, Kenneth Bruder "Philosophy: The Power of Ideas" Eighth Edition, McGrawHill, New York , 2011
៨. Manuel Velasquez " Philosophy: A text with Readings " United State, 2009

## ៩- បញ្ជីឈ្មោះគណៈកម្មការ

### គណៈកម្មការគ្រប់គ្រង

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**

៣- លោកជំទាវ **ឃុន រចនា**

៤- ឯកឧត្តម **ពុត សាមិត្ត**

៥- លោកជំទាវ **ជា សិរី**

៦- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៧- ឯកឧត្តមបណ្ឌិត **ស៊ន សេងហុក**

៨- លោក **អោ សៀម**

### គណៈកម្មការរៀបចំកម្មវិធីសិក្សាលម្អិត

១- ឯកឧត្តមបណ្ឌិត **ស៊ន សេងហុក**

២- លោកបណ្ឌិត **ម៉ុក សារ៉ុម**

៣- លោក **ឡុច ចាន់ថន**

៤- លោក **ប៉ូវ វី**

៥- លោកស្រី **នូ ចន្ទី**

៦- លោកបណ្ឌិត **ចៅ លិន**

៧- លោក **ង៉ែត ធឿន**

៨- លោក **មាស ជុតិមា**

៩- លោក **ប៉េង ទិត្យសុទ្ធី**

១០- លោក **ទែន គឹមតុន**

១១- លោកបណ្ឌិត **កាង ស៊ុងឆាង**

១២- លោក **ញឹម បាក់ងន**

១៣- លោក **សាម សារុំ**

១៤- លោក **ឡេង បូរី**

១៥- លោក **ប្រាក់ ពៅ**

១៦- លោក **ផ្លុង តូន**

១៧- លោក **ឃិន វណ្ណី**

១៨- លោក **បាន កក្កដា**

១៩- លោក **ជុំ សាម**

២០- លោកស្រី **ខូវ សោភ័ណ**

២១- លោក **សំ សែន**

២២- លោក **លុយ ឡែម**

២៣- លោក **លឹម សិរីវុឌ្ឍី**

២៤- លោក **ជា សៅវ៉ាន់ថន**

### គណៈកម្មការត្រួតពិនិត្យ

១- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន**
២- ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ សំណព្វ**
៣- ឯកឧត្តមបណ្ឌិត **ជេត ជាលី**
៤- លោកបណ្ឌិត **ម៉ុក សារ៉ុម**
៥- លោក **យិន ធី**
៦- លោក **យឹម សារិន**
៧- លោក **ស៊ុន ប៊ុណ្ណា**
៨- លោក **វ៉ា វុទ្ធី**

### លេខាធិការដ្ឋាន

១- លោកបណ្ឌិត **ម៉ុក សារ៉ុម**
២- លោកបណ្ឌិត **ជ័យ ចាន់អឿន**
៣- លោកបណ្ឌិត **ឃុន គឹមលាង**
៤- លោកបណ្ឌិត **ម៉ម សុជាតិ**
៥- លោក **អុន ស៊ីវុធថា**
៦- លោក **យិន ធី**
៧- លោក **យឹម សារិន**
៨- លោក **ហាក់ ធម្មតា**
៩- លោកស្រី **វ៉ាន់ លីណា**

### ជំនួយការបច្ចេកទេសកុំព្យូទ័រ

១- លោក **លឹម សុត្ថារិទ្ធ**
២- លោក **អេង វណ្ណារិទ្ធ**
៣- លោក **មឿន លិនណា**
៤- លោក **ជួន ចេវ**

**ចរិយាសម្បទា**

អភិវឌ្ឍបុគ្គល គ្រួសារ និងសង្គម
សហគ្រិនភាពនិងភាពជាអ្នកដឹកនាំ
ការទទួលខុសត្រូវ
កាយសុខភាព
ចិត្តសុខភាព

**វិជ្ជាសម្បទា**

អក្ខរសាស្ត្រ
លេខសាស្ត្រ
ភាសាបរទេស
បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍

**បំណិនសម្បទា**

បំណិនពិចារណានិងការបង្កើតថ្មី
ប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម
អនុវត្តចំណេះដឹងនិងជំនាញ